Cambodia has done much to improve education quality through many reforms by strengthening, among other things, the grade 12 examination, teacher education, school leadership, curriculum, the inspection system as well as student learning assessments. However, the implications of these reforms have yet to materialize in full swing. The national assessments of student learning outcomes consistently show that student performance is still below par (MoEYS, 2016; 2017; 2018). The PISA-D results also show that the majority of students at age 15 in Cambodia have poor basic skills in reading and mathematics, highlighting that learning does not take place as it is meant in the secondary education curriculum. But the fact that PISA measures students on their functional literacies accumulated from low grades (OECD, 2017) means that attention to curriculum, teaching and learning and assessment must be taken early on. Breaking this learning crisis will require strong and consistent systemic reforms from the low grades (preferably the emphasis on K-9 education).

In fact, Cambodia's participation in PISA 2021 reflects a strong commitment to excellence in its education. But, the road to strong performances in PISA will require strong and right education reforms (OECD, 2013; Schleicher, 2018). In the PISA context, teaching global knowledge and skills to retrieve, analyze and evaluate short, medium and lengthy texts, mathematic stimuli and scientific phenomena, for example, are what matters most to PISA students. In the meantime, students need routine practices of diverse learning tasks to optimize their cognitive skills (in line with Bloom's taxonomy) and to cultivate a strong reading and learning culture. But, what can be done and must be done in Cambodian education to make this happen?

The PISA-D results for Cambodia and other participating countries seem to suggest that education modalities in the past need to be revisited; in the same vein, current policies and actions have yet to directly influence student learning. Concrete actions are, in particular, not effectively in place at the school level, if any. Education systems need to be realistic to ensure students are actually learning while being in school. Successful systems such as Korea, Brazil, Estonia and even Vietnam are those committed to using the results from PISA to reform teaching and learning modalities and budget invested in education and allocation. Upgrading teacher education and ensuring firm monitoring and accountability are, in particular, the centerpiece of their strong PISA performances. Aligning what will be tested in PISA with what is taught in the class is a straightforward practice among some successful PISA countries, though not all. In this regard, Cambodia needs to find both quick wins and long-term solutions for current and future education to feed better into the global education context such as SDG and/or PISA.

### **What should policy makers do?**

This policy brief is not exhaustive in itself but desperately highlights key issues that can be done and must be done to improve student learning outcomes as well as the foundation for success in Cambodia education (Willms, 2015). The following options are worthwhile for education policy thinking, research and implementation.

- Increase and wisely use public spending in preschool and primary education to ensure students are in school and particularly mastering cognitive skills for doing lengthy and higher-order thinking reading and mathematical tasks. To this end, schools and teachers need to revisit and develop a breadth of learning tasks that promote different cognitive levels and integrate those learning tasks into classroom assessment, be it formative or summative.
- Develop or improve the system to monitor and mentor schools against pre-determined standards to establish the foundation for success.

- Continue to upgrade teacher education and teaching methods in line with the global competency framework where knowledge, skills and attitudes are promoted in teaching and learning and to support disadvantaged schools.
- Train and use surplus teachers to offer supplementary tutoring to disadvantaged and academically poor students to reduce grade repetition.
- Promote performance- and competency-based teaching and learning at the teacher training centers and school level.
- Increase learning opportunities in and outside of class by integrating supplementary learning tasks into teaching and learning. This can be done and must be done, and it is not costly.

## References

MoEYS. (2016). *Results of grade three student achievement from the national assessment in 2015.* Phnom Penh: MoEYS.

MoEYS. (2017). *Results of grade six student achievement from the national asssessment in 2016.* Phnom Penh: MoEYS.

MoEYS. (2018). *Education in Cambodia: Findings from Cambodia's experience in PISA for Development.* Phnom Penh: MoEYS.

MoEYS. (2018). *K-12 student learning assessment framework.* Phnom Penh: MoEYS.

MoEYS. (2018). *Results of grade 8 student achievement from the national asssessment in 2017.* Phnom Penh: MoEYS.

OECD. (2013). *PISA 2012 Results: What Makes Schools Successful? Resources, Policies and Practices (Volume IV).* OECD Publishing. doi:10.1787/9789264201156-en

OECD. (2016). *PISA 2015 Results (Volume I): Excellence and Equity in Education.* OECD Publishing. doi:10.1787/9789264266490-en

OECD. (2017). PISA 2015 Assessment and Analytical Framework: Science, Reading, Mathematic, Financial Literacy and Collaborative Problem Solving. In *PISA.* OECD Publishing, Paris. doi:http://dx.doi.org/10.1787/9789264281820-en

Schleicher, A. (2018). *World Class: How to build a 21st-century school system.* Paris: OECD Publishing.

UNESCO. (2015). *Student learning assessment.* Bangkok: UNESCO.

Willms, J. (2015). *Educational Prosperity.* Fredericton: The Learning Bar Inc.

World Bank. (2018). *Learning to realize education's promise.* Washington DC: World Bank.

ឯកសារសិក្សាគោលនយោបាយសង្ខេប

ការចេញផ្សាយលេខ ០១ ឆ្នាំ២០១៩

*ការបោះពុម្ពផ្សាយរបស់ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ*

ក + ខ - គ × ឃ ÷ Л ∑ ψ ∫ ф Ω ៛ $ ☺

*ការបោះផ្សាយនេះឧបត្ថម្ភដោយគម្រោងហិរញ្ញវត្ថុធនាគារអភិវឌ្ឍន៍អាស៊ី No.3427-CAM (COL)*

# តើ PISA-D ប្រាប់យើងអ្វីខ្លះអំពីការអប់រំនៅក្នុងប្រទេសកម្ពុជា?

ហេង គ្រេង, អ៊ុង ជិនណា, សរ សារិន, ជួង ចន្ថា និង តុល បញ្ញា

ទំនាក់ទំនងអ្នកនិពន្ធ | ហេង គ្រេង នាយកដ្ឋានធានាគុណភាពអប់រំ | អ៊ីម៉ែល៖ krengheng@gmail.com

## ខ្លឹមសារសំខាន់ៗ៖

- ការវាយតម្លៃការសិក្សារបស់សិស្សកម្រិតប្រព័ន្ធ ដូចជា PISA-D ផ្តល់ភស្តុតាង និងទិន្នន័យ ដែលបង្ហាញពីការសិក្សារបស់សិស្ស ក៏ដូចជាប្រព័ន្ធអប់រំទាំងមូលនៅក្នុងប្រទេសកម្ពុជា។ ជាងនេះទៅទៀត វាក៏បានបង្ហាញការអប់រំរបស់ប្រទេសកម្ពុជាទៅដល់ពិភពលោក។ យ៉ាងណាមិញ ភស្តុតាង និងទិន្នន័យត្រូវតែបកស្រាយឱ្យទៅជាគោលនយោបាយ និងការអនុវត្តផ្សេងៗ។
- កម្ពុជាត្រូវដោះស្រាយបញ្ហាប្រឈមសំខាន់មួយចំនួនទាក់ទងនឹងសមិទ្ធផលសិក្សា និងលទ្ធផលសិក្សាទាបរបស់សិស្ស និងកសាងមូលដ្ឋានគ្រឹះនៃភាពជោគជ័យនៅកម្រិតសាលារៀន។
- សិស្សប្រហែល ១០% នៃសិស្សក្នុងប្រទេសកម្ពុជាដែលមានអាយុ១៥ឆ្នាំ អាចហៅបានថា “ជាសិស្ស SDG“ លើផ្នែកអំណាន និងគណិតវិទ្យា៖ ពួកគេមានកម្រិតសមត្ថភាពអប្បបរិមា (កម្រិតទី២) លើតេស្តវាយតម្លៃ PISA-D និងអាចធ្វើការប្រៀបធៀបបានជាមួយសិស្សមួយចំនួននៅក្នុងបណ្តាប្រទេសដែលជាសមាជិក OECD។ បទពិសោធន៍ពីពួកគេ និងប្រព័ន្ធសាលារៀនរបស់ពួកគេ អាចត្រួសត្រាយឱ្យមានការអនុវត្តការគ្រប់គ្រងតាមសាលារៀនប្រកបដោយប្រសិទ្ធភាព និងបង្កើតជាម៉ូដែលមួយសម្រាប់កែលម្អលទ្ធផលសិក្សារបស់សិស្ស។
- ការចូលរួមក្នុងកម្មវិធី PISA-D និង PISA ២០២១ របស់កម្ពុជា មានន័យថាកម្មវិធីសិក្សា ការបង្រៀន និងការវាយតម្លៃត្រូវតែមានភាពស្របគ្នា និងឈានទៅរកការអប់រំដោយផ្អែកលើសមត្ថភាព (អ្វីដែលសិស្សចេះ និងអាចប្រើចំណេះទាំងនោះក្នុងការរស់នៅ និងការប្រកបការងារក្នុងសង្គមបែបទំនើប) ដើម្បីរៀបចំសិស្សសម្រាប់អនុវត្តកិច្ចការរៀនសូត្រតាមទម្រង់របស់ PISA។

## សេចក្តីផ្តើម

ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស មិនថានៅកម្រិតថ្នាក់រៀន ឬកម្រិតប្រព័ន្ធនោះទេ គឺជាធាតុគន្លឹះដ៏សំខាន់មួយក្នុងចំណោមធាតុគន្លឹះសំខាន់ផ្សេងទៀតនៅក្នុងប្រព័ន្ធអប់រំ។ វាមិនត្រឹមតែវាស់វែងអំពីសមិទ្ធផលសិក្សារបស់សិស្សតាមចំណុចដៅណាមួយនោះទេ ប៉ុន្តែវាក៏ដើរតួជាប៉ារ៉ាម៉ែត្រសម្រាប់ពិនិត្យមើលលើកម្មវិធីសិក្សា និងសម្រាប់ធ្វើការវាយតម្លៃការបង្រៀន និងរៀនផងដែរ (UNESCO, 2015) ។ និយាយឱ្យចំ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធ មានតួនាទីយ៉ាងសំខាន់ក្នុងការផ្តល់ជាព័ត៌មានផ្សេងៗអំពីអ្វីដែលដែលអាចធ្វើបាន និងអ្វីដែលត្រូវតែធ្វើដោយខានតែបាននៅក្នុងដំណើរការកំណែទម្រង់អប់រំ។ វត្តមាននៃការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធ ជាការបង្ហាញពីការធានាថា ផែនការយុទ្ធសាស្ត្រ និងសកម្មភាពផ្សេងៗនៅកម្រិតគោលនយោបាយ និងកម្រិតសាលារៀនមានភាពពាក់ព័ន្ធគ្នា ព្រមទាំងឆ្ពោះទៅរកការបង្កើនគុណភាពអប់រំ និងការអប់រំប្រកបដោយចីរភាព។

ដើម្បីត្រួតត្រាយគោលនយោបាយ និងការអនុវត្តផ្សេងៗក្នុងវិស័យអប់រំ កម្ពុជាបានខិតខំអភិវឌ្ឍប្រព័ន្ធវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធ មានតាំងពីការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិ ថ្នាក់ទី៣ ទី៦ ទី៨ និងទី១១ រហូតដល់តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់តំបន់ តេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សបឋមសិក្សានៅតំបន់អាស៊ីអាគ្នេយ៍ (SEA-PLM) និងក្នុងពេលថ្មីនេះ បានចូលរួមការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតអន្តរជាតិ ដែលមានឈ្មោះថា កម្មវិធីអន្តរជាតិស្តីពីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ PISA-D (MoEYS, 2018)។ បើទោះជាបញ្ញត្តិនៃការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធហាក់ដូចជាថ្មីនៅក្នុងប្រទេសកម្ពុជា ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធនេះកំពុងតែមានភាពចាំបាច់ខ្លាំងក្នុងកំណែទម្រង់អប់រំសព្វថ្ងៃនេះ ខណៈដែលនវានុវត្តន៍ និងការកែលម្អកម្មវិធីសិក្សា ការបង្រៀន និងរៀន និង ជាពិសេស ការគ្រប់គ្រងតាមសាលារៀន ត្រូវការភស្តុតាង និងទិន្នន័យដើម្បីបញ្ជាក់។ ប្រសិនបើធ្វើការបកស្រាយ និងប្រើប្រាស់បានត្រឹមត្រូវ នោះភស្តុតាង និងទិន្នន័យដែលបានមកពីការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធអាចតម្រែតម្រង់ការអនុវត្តដ៏ល្អ ទាំងនៅកម្រិតគោលនយោបាយ និងកម្រិតអនុវត្ត។

សេចក្តីសង្ខេបនេះពិភាក្សាអំពីតួនាទីរបស់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធក្នុងការផ្តល់ជាភស្តុតាងផ្សេងៗអំពីគោលនយោបាយ និងការអនុវត្តផ្សេងៗក្នុងការអប់រំរបស់ប្រទេសកម្ពុជាធៀបទៅនឹងកំណែទម្រង់នាពេលបច្ចុប្បន្ន និងរំលេចចេញនូវគោលនយោបាយ និងសកម្មភាពផ្សេងៗដែលជះឥទ្ធិពលដល់ការសិក្សារបស់សិស្សដោយផ្ទាល់ តាមរយៈការដាក់បញ្ចូលគ្នានូវភស្តុតាងដែលបានមកពីបទពិសោធន៍របស់កម្ពុជាក្នុងការចូលរួមជាមួយកម្មវិធីវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតអន្តរជាតិ ដែលត្រូវគេស្គាល់ជាសកលថា PISA-D (MoEYS, 2018)។ ឯកសារនេះក៏បានវិភាគទៅលើស្ថានភាពការអប់រំនាពេលបច្ចុប្បន្ន ក្នុងបរិបទ PISA 2021 ដោយពិភាក្សាសំខាន់ លើសំណួរដូចជា តើ PISA 2021 មានន័យអ្វីខ្លះចំពោះកម្ពុជា? តើយើងទៅដល់ណា ពីស្ថានភាពអប់រំនាពេលបច្ចុប្បន្ន?

## កម្ពុជាក្នុងបរិបទ PISA-D និងអប់រំសកល

កម្ពុជាបានចូលរួមក្នុងកម្មវិធី PISA-D នៅក្នុងឆ្នាំ២០១៦ ជាមួយនឹងប្រទេសចំនួន៨ផ្សេងទៀតជាសមាជិក (អេក្វាទ័រ ប៊ូតង់ ក្វាតេម៉ាឡា សំប៊ី សេណេហ្គាល់ ប៉ារាហ្គាយ ហុងឌុយរ៉ាស និងប៉ាណាម៉ា)។ PISA-D ជាកម្មវិធីថ្មីសម្រាប់ប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យម និង ភាគច្រើន យកលំនាំតាមទម្រង់របស់តេស្ត PISA ដែលជាការស្ទង់មតិកម្រិតអន្តរជាតិ ធ្វើឡើងក្នុងរយៈពេល៣ឆ្នាំម្តង និងមានគោលបំណងចម្បង ដើម្បីវាយតម្លៃប្រព័ន្ធអប់រំទូទាំងសកលលោក ដោយធ្វើតេស្តទៅលើចំណេះដឹង និងបំណិនរបស់សិស្សអាយុ១៥ឆ្នាំ ដែលកំពុងសិក្សានៅកម្រិតថ្នាក់ពីទី៧ឡើងទៅ។ PISA-D វាយតម្លៃទៅលើកម្រិតដែលសិស្សអាយុ១៥ឆ្នាំ (ជិតចប់ការអប់រំកម្រិតមូលដ្ឋាន) ទទួលបានចំណេះដឹង និងបំណិនសំខាន់ៗ សម្រាប់ការចូលរួមពេញលេញទាំងការងារ និងការរស់នៅក្នុងសង្គមទំនើប។ ការវាយតម្លៃផ្តោតលើមុខវិជ្ជាស្នូលក្នុងសាលារៀនដូចជា វិទ្យាសាស្ត្រ អំណាន និងគណិតវិទ្យា និងមិនគ្រាន់តែសង្កត់ធ្ងន់លើថាតើសិស្សអាចបង្កើតឡើងវិញនូវចំណេះដឹងដែលមានក្នុងសាលារៀន ប៉ុន្តែក៏បានធ្វើការវាស់វែងថាតើសិស្សអាចទាញយកពីអ្វីដែលពួកគេបានសិក្សា និងអាចយកចំណេះដឹងទាំងនោះទៅអនុវត្តក្នុងបរិបទដែលមិនធ្លាប់ស្គាល់ ទាំងក្នុង និងក្រៅសាលារៀន។ គោលវិធីនេះឆ្លុះបញ្ចាំងពីការពិតអំពីប្រទេសដែលមានសេដ្ឋកិច្ចទំនើបផ្តល់រង្វាន់ដល់អ្នកណាម្នាក់ ដោយមិនផ្តោតទៅលើអ្វីដែលពួកដឹង ប៉ុន្តែផ្តោតទៅលើអ្វីដែលពួកគេអាចធ្វើបានជាមួយអ្វីដែលពួកគេដឹង។

PISA-D វាយតម្លៃសិស្សកម្ពុជាចំនួន៥១៦២នាក់ ជាតំណាងឱ្យសិស្សអាយុ១៥ឆ្នាំទូទាំងប្រទេសដែលកំពុងសិក្សាចាប់ពីថ្នាក់ទី៧ឡើងទៅ។ សិស្សទាំងនេះតម្រូវឱ្យអង្គុយធ្វើតេស្តរយៈពេល២ម៉ោង និងបំពេញកម្រងសំណួរអំពីបរិបទជុំវិញ ដើម្បីវាស់វែងពីកត្តាផ្សេងៗដែលមានឥទ្ធិពលទៅលើការសិក្សារបស់ពួកគេ ដូចជា សាលារៀន ថ្នាក់រៀន ផ្ទះ និងបរិយាកាសសហគមន៍ជាដើម។ ការចូលរួមក្នុងកម្មវិធី PISA-D មានន័យថា ការអប់រំរបស់ប្រទេសកម្ពុជា មិនត្រឹមតែមានទំនាក់ទំនងនឹងបរិបទប្រទេសរបស់ខ្លួនប៉ុណ្ណោះទេ តែក៏មានទាក់ទងនឹងនិន្នាការអប់រំសកលផងដែរ ជាពិសេស ទាក់ទងទៅនឹងគោលដៅអប់រំសកលដូចដែលបានចង្អុលបង្ហាញនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ខណៈដែលកម្រិតសមត្ថភាពមូលដ្ឋានជាសកល គឺជាអ្វីដែលប្រទេសនីមួយៗចង់បាន (MoEYS, 2018) ។ ទន្ទឹមគ្នានេះដែរ ការចូលរួមនេះក៏ជាការឱកាសមួយដើម្បីឱ្យកម្ពុជារៀបចំខ្លួនឱ្យបានប្រសើរឡើងសម្រាប់កម្មវិធី PISA ២០២១។ ដូចនេះ លទ្ធផលពី PISA-D បានសារៈសំខាន់ណាស់សម្រាប់កំណែទម្រង់អប់រំនៅកម្ពុជា និងលទ្ធផលសិក្សារបស់សិស្សសម្រាប់វដ្ត PISA បន្ទាប់ទៀតនេះ។ បើទោះជាដូច្នេះក៏ដោយ តែការអប់រំនៅកម្ពុជាត្រូវដោះស្រាយបញ្ហាប្រឈមធំចំនួនពីរធំៗគឺ ទីមួយ ត្រូវធ្វើយ៉ាងណាឱ្យឆ្លើយតបទៅនឹងតម្រូវការក្នុងស្រុក និងមួយវិញទៀត ត្រូវបន្ស៊ីខ្លួនឯងទៅហ្នឹងបរិបទនៃការអប់រំសកល។ ចំណុចនេះត្រូវការឱ្យមាននវានុវត្តន៍នៃការបង្រៀន និងរៀនដែលជំរុញនូវ "របៀបបង្រៀន និងរៀន" ជាជាងការផ្តោតតែលើ "អ្វីដែលត្រូវបង្រៀន និងរៀន"។ ភស្តុតាង និងទិន្នន័យពីការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សកម្រិតប្រព័ន្ធពិតជាត្រូវការជាចាំបាច់សម្រាប់ប្រទេសកម្ពុជា។

## តើ PISA-D ប្រាប់យើងអ្វីខ្លះអំពីការអប់រំនៅក្នុងប្រទេសកម្ពុជា?

### *សមិទ្ធផលសិក្សាសម្រេចបាន និងលទ្ធផលសិក្សា*

លទ្ធផល PISA-D បង្ហាញថា ប្រទេសកម្ពុជាប្រឈមបញ្ហាចំនួនពីរក្នុងពេលដំណាលគ្នា នៅក្នុងប្រព័ន្ធអប់រំរបស់ខ្លួនគឺសិស្សអាយុ១៥ឆ្នាំមិនត្រឹមតែសម្រេចបាននូវការអប់រំទាបប៉ុណ្ណោះទេ ថែមទាំងលទ្ធផលសិក្សាមិនល្អផងដែរ។ ចំពោះលទ្ធផល

សិក្សាសម្រេចបានរបស់សិស្ស ប្រទេសកម្ពុជាត្រូវការរយៈពេលវែងដើម្បីបន្ថយគម្លាតអត្រាចូលរៀននៅកម្រិតមធ្យមសិក្សា បើធៀបនឹងប្រទេសដែលជាសមាជិក PISA-D ASEAN និង OECD ។ សិស្សអាយុ១៥ឆ្នាំ ដែលកំពុងសិក្សាពីថ្នាក់ទី៧ដល់១២នៅក្នុងប្រទេសកម្ពុជា មានតែចំនួន ២៨.១% នៃសិស្សអាយុ១៥ទាំងអស់នៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ដែលមានន័យថា សិស្សដែលមានអាយុ១៥ឆ្នាំ ប្រហែលជា៧២% បានបោះបង់ការសិក្សា ឬមានការយឺតយ៉ាវក្នុងការចូលរៀន ជាពិសេស សិស្សប្រុស។ សមិទ្ធផលសិក្សាសម្រេចបានរបស់សិស្សអាយុ១៥ឆ្នាំនៅក្នុងប្រទេសកម្ពុជាអាចប្រៀបធៀបបានជាមួយប្រទេសសេណេហ្គាល់ និងសំប៊ី ដែលយុវជនភាគច្រើនស្ថិតនៅក្រៅសាលារៀន ប៉ុន្តែទាបជាងខ្លាំងបើធៀបនឹងប្រទេស អេក្វាទ័រ (៦១%) ប៉ារ៉ាហ្គាយ (៥៦%) ក្វាតេម៉ាឡា (៤៧%) និងហុងឌុយរ៉ាស (៤១%)។ សមិទ្ធផលសិក្សាសម្រេចបានកម្រិតទាបបែបនេះ ធ្វើឱ្យឱកាសការងាររបស់សិស្សថយចុះ និងជាបញ្ហាប្រឈមមួយក្នុងការខិតខំបង្កើនកម្លាំងពលកម្ម ដើម្បីគាំទ្រដល់ទម្រង់សេដ្ឋកិច្ចដែលប្រទេសកម្ពុជាចង់បានឱ្យក្លាយទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ២០៥០ ខាងមុខនេះ។ សមិទ្ធផលសិក្សាទាបរបស់សិស្សអាយុ១៥ឆ្នាំ ក៏មានន័យថា កម្ពុជាត្រូវរៀបចំវិធានការដែលមានប្រសិទ្ធភាពបន្ថែមទៀត ដើម្បីធានាឱ្យសិស្សមានឱកាសបញ្ចប់យ៉ាងហោចណាស់ត្រឹមកម្រិតមធ្យមសិក្សាបឋមភូមិ (ការអប់រំកម្រិតមូលដ្ឋាន ៩ឆ្នាំ)។

សមិទ្ធផលសិក្សាសម្រេចបានទាបនៅកម្រិតមធ្យមសិក្សានេះបង្ហាញថា សិស្សចូលរៀនយឺត រៀនត្រួតថ្នាក់ ឬបោះបង់ការសិក្សាចាប់តាំងពីកម្រិតបឋមសិក្សាមកម្លេះ។ នៅក្នុងប្រព័ន្ធអប់រំនៃប្រទេសដែលមានសេដ្ឋកិច្ចកំពុងអភិវឌ្ឍន៍ សិស្សដែលមានសមត្ថភាពទាបប្រហែលជាមិនអាចឆ្លងភូមិសិក្សាដូចសិស្សដទៃបានទេ។ សិស្សដែលអាចបន្តការសិក្សាបាន ជាទូទៅពួកគេជាសិស្សដែលមានការតស៊ូ ឬមានប្រវត្តិនៃការសិក្សាខ្លាំង។ ការគិតបែបនេះគឺផ្អែកលើភស្តុតាងក្នុងករណីប្រទេសវៀតណាម ខណៈអត្រាសិស្សអាយុ១៥ឆ្នាំដែលបានចូលរួមក្នុងកម្មវិធី PISA គឺមានប្រហែលជា ៤៨% ប៉ុណ្ណោះ តិចជាងច្រើនបើធៀបនឹងមធ្យមភាគរបស់ OECD (៨៩%) ប៉ុន្តែប្រទេសវៀតណាមទទួលបានលទ្ធផលល្អជាងបណ្តាប្រទេសដែលសមាជិក OECD ជាច្រើនលើផ្នែកវិទ្យាសាស្ត្រ នៅក្នុងកម្មវិធី PISA ២០១២ និង២០១៥។ អ្នកបង្កើតគោលនយោបាយជាច្រើនគ្រើនរំលឹកថា លទ្ធផលល្អរបស់ប្រទេសវៀតណាមអាចបង្ហាញពីភាពជោគជ័យមួយក្នុងប្រព័ន្ធអប់រំ ប៉ុន្តែទាមទារឱ្យមានការវិភាគបន្ថែមដើម្បីផ្ទុះបញ្ជាំងការពិតនៃប្រព័ន្ធអប់រំទាំងមូល ក្នុងហេតុផលថា ប្រព័ន្ធនោះប្រហែលជារក្សាបានតែសិស្សពូកែប៉ុណ្ណោះ ខណៈដែលទុកសិស្សផ្សេងទៀតឱ្យបោះបង់ការសិក្សា។ តែយ៉ាងណាក៏ដោយ ក្នុងស្ថានភាព ស្រដៀងគ្នានៃសមិទ្ធផលសិក្សាសម្រេចបាន ប្រទេសកម្ពុជាមិនសម្រេចបានដូចទៅនឹងភាពជោគជ័យរបស់ប្រទេសវៀតណាមទេ ហើយត្រូវដោះស្រាយបញ្ហាប្រឈមធំពីរ គឺសមិទ្ធផលសិក្សាសម្រេចបានទាប និងលទ្ធផលសិក្សាទាបផងដែរ។

*រូបភាពទី 1៖ សមិទ្ធផលសិក្សាសម្រេចបានរបស់សិស្សអាយុ១៥ឆ្នាំ ចាប់ពីថ្នាក់ទី៧ឡើងទៅ*




ប្រភព៖ ទិន្នន័យ PISA 2015 និង PISA-D

លទ្ធផល PISA-D បង្ហាញថា កម្ពុជាមានអ្វីៗជាច្រើនដែលត្រូវធ្វើបន្តទៀតដើម្បីធ្វើឱ្យពិន្ទុ PISA បានល្អ បើទោះជាសិស្សអាយុ១៥ឆ្នាំនៅក្នុងប្រទេសកម្ពុជាទទួលបានលទ្ធផលល្អជាងសិស្សអាយុដូចគ្នានៅក្នុងប្រទេសសេណេហ្គាល់ និងសំប៊ី លើគ្រប់មុខវិជ្ជាក៏ដោយ។ អ្វីដែលយើងអាចមើលឃើញនោះគឺ លើផ្នែកអំណាន និងវិទ្យាសាស្ត្រ សិស្សកម្ពុជាអាយុ១៥ឆ្នាំជាមធ្យមទទួលបានលទ្ធផលសិក្សាទាបនៅឡើយ បើធៀបនឹងសិស្សនៅក្នុងប្រទេសដែលជាសមាជិក PISA-D និង ASEAN ផ្សេងទៀត(វៀតណាម ថៃ ឥណ្ឌូនេស៊ី និងសាំងហ្គាពួរ)។ សាលារៀនតាមជនបទ ប្រជុំជន និងសាលារៀនដែលមានធនធានខ្វះខាតនៅក្នុងប្រទេសកម្ពុជាទទួលបានលទ្ធផលសិក្សាកាន់តែទាប។ ទិដ្ឋភាពរួមមួយដែលគួរកត់សម្គាល់ពី PISA-D គឺថា សាលារៀនឯកជនទទួលបានលទ្ធផលសិក្សារបស់សិស្សខ្ពស់ជាងសាលារៀនរដ្ឋ រហូតដល់ទៅប្រហែល២ឆ្នាំសិក្សា។ ភាពខុសគ្នានៃលទ្ធផលសិក្សានេះ បង្ហាញអំពីវិសមភាពនៃការអប់រំនៅក្នុងប្រព័ន្ធទាំងពីរ។

សិស្សកម្ពុជាទទួលបាន ៣២១ពិន្ទុ លើផ្នែកអំណាន និង៣៣០សម្រាប់ផ្នែកវិទ្យាសាស្ត្រ ខណៈដែលពិន្ទុសរុបខ្ពស់បំផុតប្រហែលជា៧០០ពិន្ទុ។ ជាមធ្យម សិស្សនៅក្នុងបណ្ដាប្រទេសសមាជិក PISA-D ទទួលបាន៣៤៦ពិន្ទុ លើផ្នែកអំណាន និង៣៤៩ពិន្ទុ លើផ្នែកវិទ្យាសាស្ត្រ។ មធ្យមភាគសិស្សអាយុ១៥ឆ្នាំតាមបណ្ដាប្រទេសនៅក្នុងASEAN ទទួលបាន ៤៣០ពិន្ទុ លើផ្នែកអំណាន និង៤៤៧ពិន្ទុ លើផ្នែកវិទ្យាសាស្ត្រ (OECD, 2013; OECD, 2016); ខណៈដែលមធ្យមភាគសិស្សនៅក្នុងបណ្ដាប្រទេសសមាជិក OECD ទទួលបានដល់ទៅប្រហែល ៤៩០ពិន្ទុ លើគ្រប់ផ្នែកទាំងអស់ ដែលសមមូលទៅនឹងកម្រិតទី៣ នៃកម្រិតសមត្ថភាពទាំង៦

របស់ PISA។ ពិន្ទុ ៤១០ ឬខ្ពស់ជាងនេះ បង្ហាញថាសិស្សសម្រេចបានកម្រិតសមត្ថភាពអប្បរមា ឬកម្រិតមូលដ្ឋាន (កម្រិតទី២) ស្របគ្នាទៅនឹងការរំពឹងទុកនៅក្នុងក្របខណ្ឌ SDG4។

កម្រិតសមត្ថភាពទី២ គឺជាកម្រិតលទ្ធផលសិក្សាមូលដ្ឋានរបស់កម្មវិធី PISA-D ឬ PISA។ ក្នុងកម្រិតនេះ សិស្សអាចស្វែងរកព័ត៌មាននៅក្នុងអត្ថបទអំណាន ឬតារាងស្ថិតិ ងាយយល់អំពីគំនិតគន្លឹះរបស់អត្ថបទដោយផ្អែកលើព័ត៌មានតិចតួចដែលបានផ្តល់ជូន (ពួកគេអាចធ្វើសេចក្តីសន្និដ្ឋានបាន) ធ្វើការប្រៀបធៀប និងឆ្លុះបញ្ចាំងទៅលើខ្លឹមសារអត្ថបទនៅក្នុងពិភពពិត។ ក្នុងករណីគណិតវិទ្យា សិស្សអាចយកទ្រឹស្តីទូទៅ ឬរូបមន្តគណិតវិទ្យាទៅអនុវត្ត ដោះស្រាយបញ្ហា ឬគណនាលេខនៅក្នុងការងារ ឬបរិបទស្ថានភាពនៃជីវិតពិត ដូចជាអត្រាប្តូរប្រាក់ ល្បឿន ឬចម្ងាយចរ និងពន្យល់ ឬបកស្រាយលទ្ធផលដែលរកឃើញជាដើម។ ចំពោះវិទ្យាសាស្ត្រ សិស្សអាចយកខ្លឹមសារ និងដំណើរការ ឬនិតិវិធីផ្សេងៗ ទៅអនុវត្ត ពន្យល់ ឬបកស្រាយទិន្នន័យ និងបាតុភូតផ្សេងៗ នៅក្នុងធម្មជាតិ ឬស្ថានភាពជីវិតពិត ដូចជា កម្លាំងកកិត ទំនាញផែនដី និងអត្ថប្រយោជន៍លំហាត់សាច់ដុំ ឬសរសៃឈាមជាដើម។

ដោយប្រៀបធៀបជាមួយប្រទេសជាសមាជិក PISA-D ផ្សេងទៀត កម្រិតសមត្ថភាពរបស់សិស្សនៅក្នុងប្រទេសកម្ពុជាអាចនិយាយបានថា នៅកម្រិត “ទាប” ដែលក្នុងនោះសិស្សអាយុ១៥ឆ្នាំប្រហែលតែ ៨% ទៅ ១០% ប៉ុណ្ណោះទទួលបានសមត្ថភាពកម្រិតមូលដ្ឋាន (កម្រិតទី២) លើផ្នែកអំណាន និងគណិតវិទ្យា ខណៈដែលផ្នែកវិទ្យាសាស្ត្រ មានតែប្រមាណ ៥% ប៉ុណ្ណោះដែលឈានដល់កម្រិតសមត្ថភាពនេះ។ ដូចនេះសិស្សនៅកម្ពុជាមួយចំនួនតូចប៉ុណ្ណោះមានជំនាញមូលដ្ឋានសកល ដែលសម្រេចបានគោលដៅអប់រំក្នុងបរិបទ គោលដៅអប់រំប្រកបដោយចីរភាព (SDG4)។ កម្រិតសមត្ថភាពរបស់សិស្សអាចទាបជាងនេះ បើសិស្សអាយុ១៥ឆ្នាំដែលនៅស្ថិតនៅក្រៅសាលារៀនត្រូវបានបញ្ចូលនៅក្នុងសំណាក1 (MoEYS, 2018)។ ទោះជាយ៉ាងណាក៏ដោយសិស្សទាំងនោះ អាចហៅថា “សិស្ស SDG” ដែលអាចប្រៀបធៀបបានសូម្បីតែជាមួយសិស្សមកពីបណ្តាប្រទេសដែលជាសមាជិក OECD។ ដើម្បីលុបបំបាត់គម្លាតលទ្ធផលសិក្សា កម្ពុជាត្រូវរៀនសូត្រពីលទ្ធផលសិក្សា ព្រមទាំងពីប្រព័ន្ធអប់រំរបស់គេយកជាចំណុចត្រូវរៀន និងជាផ្លូវទៅមុខទៀត ដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្សក្នុងដំណើរដ៏វែងឆ្ងាយ។

រូបភាពទី 2៖ ភាគរយសិស្សអាយុ១៥ឆ្នាំនៅកម្រិតសមត្ថភាពអប្បរមា

[1] កម្រិតការសិក្សាទាបនេះត្រូវបានពិភាក្សាដោយ Michelle Kaffenberger, អ្នកស្រាវជ្រាវជាន់ខ្ពស់នៅក្នុងកម្មវិធី RISE តាមរយៈ https://www.riseprogramme.org/blog/PISA-D_low_learning.




ប្រភព៖ ទិន្នន័យ PISA 2015 និង PISA-D

## *ការចូលរៀន និងបញ្ហាគុណភាព*

ទោះផ្អែកលើរង្វាស់ណាក៏ដោយ កម្ពុជានៅទាបជាងឆ្ងាយធៀបទៅនឹងកម្រិតសមត្ថភាពមូលដ្ឋានដែលបានកំណត់ជាសកល ដែលមានន័យថា កម្ពុជាត្រូវការគោលនយោបាយ និងសកម្មភាពឆ្លើយតបជាក់លាក់បន្ថែមទៀតដើម្បីដោះស្រាយវិបត្តិអប់រំបច្ចុប្បន្ន។ កំណែទម្រង់ដែលមានប្រសិទ្ធភាព និងរយៈពេលយូរអាចនឹងធ្វើឱ្យសិស្សអាយុ១៥ឆ្នាំ នៅកម្ពុជាទទួលបានលទ្ធផលល្អជាងនេះ យ៉ាងហោចណាស់ទទួលបានកម្រិតសមត្ថភាពទី២ ដោយសារសិស្សកម្ពុជាប្រហែល ៣៥% ស្ថិតក្នុងកម្រិតទី១ក (កម្រិតខ្ពស់បំផុតនៃកម្រិតទី១ និងជិតបំផុតទៅនឹងកម្រិតទី២) លើផ្នែកអំណាន និងប្រហែលជា៤២% នៅក្នុងកម្រិតទី១ក សម្រាប់ផ្នែកវិទ្យាសាស្ត្រ។ បន្ថែមពីលើនេះទៀត ដោយផ្អែកលើរង្វាស់ផ្សេងៗលទ្ធផល PISA-D បង្ហាញថា នៅក្នុងប្រទេសកម្ពុជា សិស្សគិតថា ការចូលរៀនគឺជា “សំណាងរបស់ពួកគេ” ដូចជាសិស្សមានអារម្មណ៍ថាខ្លួនគេជាចំណែកមួយរបស់សាលារៀន មានការពេញចិត្តនឹងជីវិតខ្ពស់ និងមានឥរិយាថវិជ្ជមានចំពោះសាលារៀន និងការសិក្សា ដែលនេះជាភាគលាភមួយសម្រាប់ការរីកចម្រើន និងអភិវឌ្ឍន៍ (MoEYS, 2018)។ តែទោះជាយ៉ាងណាក៏ដោយ “ការដែលសិស្សបានចូលរៀនគឺមិនដូចគ្នាទៅនឹងសិស្សបានរៀនសូត្រនោះទេ” (World Bank, 2018)។ ទោះបីការងារជាច្រើនកម្ពុជាបានធ្វើកន្លងមក តែទិន្នន័យ PISA-D បង្ហាញថា កម្ពុជាត្រូវដោះស្រាយបញ្ហាបន្ទាន់ជាច្រើននៅក្នុងកម្រិតសាលារៀន ជាពិសេសបញ្ហាសិស្សរៀនត្រួតថ្នាក់ អវត្តមាន ភាពយឺតយ៉ាវរបស់គ្រូ និងសិស្ស គុណភាពគ្រប់គ្រងសាលារៀនមិនល្អ ខ្វះវប្បធម៌ប្រឹងប្រែងរៀនសូត្រ និងការបែងចែកធនធានមិនស្មើភាពគ្នា រាប់

តាំងពីការបែងចែកគ្រូមិនស្មើគ្នាជាដើម។ កម្ពុជាក៏ត្រូវលុបបំបាត់គម្លាតនៃការអប់រំ និងអភិវឌ្ឍន៍គ្រូជាមួយនឹងប្រទេសសមាជិក PISA-D ASEAN និង OECD។ ទិន្នន័យ PISA-D បង្ហាញថា គុណវុឌ្ឍិគ្រូបង្រៀននៅកម្ពុជាគឺនៅមានកម្រិតទាបនៅឡើយ បើធៀបទៅនឹងប្រទេសសមាជិក PISA-D ASEAN និង OECD ផ្សេងទៀត ដែលក្នុងបណ្ដាប្រទេសទាំងនោះ គ្រូបង្រៀននៅមធ្យមសិក្សាភាគច្រើនមានសញ្ញាបត្រយ៉ាងហោចណាស់ត្រឹមបរិញ្ញាបត្រ។

លទ្ធផលសិក្សាទាបរបស់សិស្សអាយុ១៥ឆ្នាំនៅក្នុងប្រទេសកម្ពុជា ក៏មានន័យដែរថា កម្ពុជាត្រូវការវិនិយោគបន្ថែមទៀត ជាពិសេសទៅលើការអប់រំកុមារតូច និងបឋមសិក្សា និងគាំទ្រដល់សាលារៀនដែលខ្វះខាតបុគ្គលិក និងខ្វះខាតធនធាន ដែលជាទូទៅជាសាលារៀននៅតាមជនបទ។ ការធ្វើឱ្យមានតុល្យការថវិកាអប់រំឡើងវិញ ប្រហែលជាអាចជួយកាត់បន្ថយការចំណាយលើការអប់រំបន្ថែម(បំប៉ន) ឬការបោះបង់ការសិក្សារបស់សិស្សនៅថ្នាក់ខ្ពស់។ យោងលើទិន្នន័យ PISA-D ការវិនិយោគលើវិស័យអប់រំនៅក្នុងប្រទេសកម្ពុជានៅមានកម្រិតទាប (២.៧% នៃ ផ.ស.ស) នៅក្នុងតំបន់ និង PISA-D ដោយមិនទាន់គិតពីការជាក់ស្ដែងមួយទៀតដោយភាគច្រើននៃថវិកាត្រូវចំណាយទៅលើប្រាក់ខែគ្រូបង្រៀន។ ជារួម កម្ពុជាត្រូវធ្វើដំណើរវែងឆ្ងាយដើម្បីធ្វើឱ្យមានមូលដ្ឋានគ្រឹះសម្រាប់ភាពជោគជ័យ នៅកម្រិតសាលារៀន (Willms, 2015)។ គោលនយោបាយ និងសកម្មភាពជាក់លាក់ដែលមានផលជះផ្ទាល់ដល់ការគ្រប់គ្រងសាលារៀន និងការសិក្សារបស់សិស្ស វាជាការឆ្លើយតបដ៏ត្រឹមត្រូវ និងរយៈពេលវែងមួយ។

## **ទិដ្ឋភាពអប់រំនៅក្នុងបរិបទ** PISA៖ **តើត្រូវទៅណា**?

កម្ពុជាបានធ្វើអ្វីជាច្រើនដើម្បីបង្កើនគុណភាពអប់រំ តាមរយៈកំណែទម្រង់ផ្សេងៗ ដោយពង្រឹងក្នុងចំណោមការងារផ្សេងទៀត ការប្រឡងថ្នាក់ទី១២ ការអប់រំគ្រូ ការដឹកនាំសាលារៀន កម្មវិធីសិក្សា ប្រព័ន្ធអធិការកិច្ចក៏ដូចជាការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សជាដើម។ ប៉ុន្តែអ្វីដែលចង់បានពីកំណែទម្រង់ទាំងនេះមិនទាន់បានសម្រេចចេញជារូបរាងពេញលេញនៅឡើយទេ។ ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សថ្នាក់ជាតិបង្ហាញដូចៗគ្នាថា លទ្ធផលសិក្សារបស់សិស្សនៅមានកម្រិតទាបនៅឡើយ (MoEYS, 2016; 2017; 2018)។ លទ្ធផលPISA-D បង្ហាញទៀតថា សិស្សអាយុ១៥ឆ្នាំរបស់កម្ពុជាភាគច្រើនខ្វះបំណិនមូលដ្ឋានលើផ្នែកអំណាន និងគណិតវិទ្យា ដែលចំណុចនេះរំលេចថា ការសិក្សារៀនសូត្រមិនបានកើតឡើងស្របតាមអ្វីដែលកំណត់នៅក្នុងកម្មវិធីសិក្សានៅមធ្យមសិក្សានៅឡើយទេ។ ប៉ុន្តែ ការពិតមួយដែល PISA ធ្វើការវាស់វែងសិស្សទៅលើអក្ខរកម្មសម្រាប់អនុវត្តក្នុងស្ថានភាពជាក់ស្ដែងដែលសិស្សទទួលបានចាប់តាំងពីកម្រិតថ្នាក់ទាបមក (OECD, 2017) មានន័យថា កម្ពុជាត្រូវយកចិត្តទុកដាក់ទៅលើកម្មវិធីសិក្សា ការបង្រៀន និងរៀន និងការវាយតម្លៃ ដែលអនុវត្តក្នុងបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ។ ការដោះស្រាយបញ្ហានេះ ត្រូវការកំណែទម្រង់ប្រព័ន្ធអប់រំស៊ីជំរៅ និងមានសង្គតភាព ពីការអប់រំកម្រិតថ្នាក់ក្រោមមក (គួរតែសង្កត់ធ្ងន់លើអប់រំកម្រិតមូលដ្ឋាន)។

ជាការពិត ការចូលរួមរបស់ប្រទេសកម្ពុជានៅក្នុងកម្មវិធី PISA ២០២១ ឆ្លុះបញ្ចាំងពីការតាំងចិត្តខ្ពស់ក្នុងដំណើរឆ្ពោះទៅរកឧត្តមភាពនៅក្នុងប្រព័ន្ធអប់រំ។ ប៉ុន្តែផ្លូវឆ្ពោះទៅកាន់ការទទួលបានលទ្ធផលល្អនៅក្នុងកម្មវិធី PISA ត្រូវការកំណែទម្រង់មួយដ៏ស៊ីជំរៅ និងត្រឹមត្រូវ (OECD, 2013; Schleicher, 2018)។ នៅក្នុងបរិបទ PISA ការបង្រៀនឱ្យសិស្សមានចំណេះដឹង និង

ជំនាញសកល ក្នុងការទាញយកព័ត៌មាន វិភាគ និងវាយតម្លៃអត្ថបទខ្លីៗ មធ្យម និងវែងៗ ដោះស្រាយលំហាត់គណិតវិទ្យា និងបាតុភូតវិទ្យាសាស្ត្រផ្សេងៗ គឺជាអ្វីដែលល្អបំផុតសម្រាប់សិស្សដែលធ្វើតេស្ត PISA។ ទន្ទឹមនឹងនេះ សិស្សត្រូវតែអនុវត្តកិច្ចការ ឬលំហាត់ផ្សេងៗដែលមានលក្ខណៈច្រើនប្រភេទ ជាប្រចាំ ដើម្បីធ្វើឱ្យប្រសើរឡើងនូវបំណិននៃការគិតរបស់ពួកគេ (ស្របគ្នានឹងកម្រិតនៃការគិតរបស់លោកប្លូម) និងបណ្ដុះវប្បធម៌អាន និងរៀនសូត្រដោយខ្លួនឯង។ ប៉ុន្តែ តើអ្វីទៅដែលយើងអាចធ្វើបាន និងត្រូវតែធ្វើសម្រាប់ការអប់រំនៅកម្ពុជាដើម្បីធ្វើឱ្យរឿងទាំងនេះកើតឡើងពិតប្រាកដ?

លទ្ធផល PISA-D សម្រាប់ប្រទេសកម្ពុជា និងប្រទេសជាសមាជិកផ្សេងទៀតហាក់ដូចជាបង្ហាញផ្លូវថា បែបបទអប់រំនាពេលកន្លងមកត្រូវការការពិនិត្យឡើងវិញ ហើយដូចគ្នាដែរគោលនយោបាយ និងការអនុវត្តនាពេលបច្ចុប្បន្ននៅមិនទាន់មានឥទ្ធិពលដោយផ្ទាល់លើការរៀនសូត្ររបស់សិស្សនៅឡើយទេ។ និយាយឱ្យចំ សកម្មភាពមួយចំនួន បើទោះជាមាន គឺមិនទាន់ដំណើរការប្រកបដោយប្រសិទ្ធភាពនៅក្នុងកម្រិតសាលារៀននៅឡើយទេ។ ប្រព័ន្ធអប់រំមួយត្រូវតែធានាថា សិស្សពិតជារៀនសូត្រពិតប្រាកដមែន នៅពេលដែលពួកគេបានចុះឈ្មោះចូលរៀនរួច។ ប្រព័ន្ធអប់រំដែលជោគជ័យ ដូចជាប្រទេសកូរ៉េ ប្រេស៊ីល អេស្តូនៀ និងសូម្បីតែវៀតណាម គឺជាប្រព័ន្ធដែលមានការតាំងចិត្តខ្ពស់ក្នុងការប្រើប្រាស់លទ្ធផលរបស់ PISA ដើម្បីកែលម្អការបង្រៀន និងរៀន ព្រមទាំងការវិនិយោគ និងការបែងចែកថវិកានៅក្នុងវិស័យអប់រំ។ ការបង្កើនការអប់រំរបស់គ្រូ និងការធានាឱ្យមានប្រព័ន្ធពិនិត្យតាមដាន និងគណនេយ្យភាពដ៏រឹងមាំមួយ គឺជាចំណុចគន្លឹះដែលនាំឱ្យប្រទេសទាំងនោះទទួលបានលទ្ធផលសិក្សា PISA ខ្ពស់។ ការធ្វើឱ្យមានភាពស្របគ្នានូវអ្វីដែលត្រូវធ្វើតេស្ត និងអ្វីដែលត្រូវបង្រៀននៅក្នុងថ្នាក់ គឺជាការអនុវត្តដែលចំចំណុចក្នុងចំណោមប្រទេសដែលជោគជ័យក្នុងកម្មវិធី PISA បើទោះជាមិនទាំងអស់ក៏ដោយ។ តាមរយៈនេះ កម្ពុជាត្រូវការរកឱ្យឃើញទាំងពីរនូវដំណោះស្រាយធ្វើលឿនបានផលលឿន និងដំណោះស្រាយរយៈពេលវែងសម្រាប់ការអប់រំបច្ចុប្បន្ន និងនាពេលអនាគត ដើម្បីបន្សុីការអប់រំរបស់ខ្លួនទៅនឹងបរិបទសកលឱ្យកាន់តែប្រសើរឡើងដូចជា SDG ឬPISA ជាដើម។

## តើអ្វីខ្លះដែលអ្នកគោលនយោបាយគួរធ្វើ?

សង្ខេបគោលនយោបាយនេះ គឺមិនបានលម្អិតគ្រប់គ្រាន់ទេ តែបានរំលេចចេញនូវបញ្ហាគន្លឹះមួយចំនួនដែលអាចធ្វើបាន និងត្រូវតែធ្វើ ដើម្បីបង្កើនលទ្ធផលសិក្សារបស់សិស្ស ក៏ដូចជាបង្កើននូវមូលដ្ឋានគ្រឹះសម្រាប់ភាពជោគជ័យនៃការអប់រំនៅប្រទេសកម្ពុជា (Willms, 2015)។ ជម្រើសខាងក្រោមនេះគឺមានប្រយោជន៍សម្រាប់គិតអំពីគោលនយោបាយអប់រំ ការសិក្សាស្រាវជ្រាវ និងការអនុវត្តផ្សេងៗក្នុងកំណែទម្រង់អប់រំ៖

- បង្កើន និងប្រើប្រាស់ឱ្យបានទូលំទូលាយនូវការចំណាយរបស់រដ្ឋលើការអប់រំនៅក្នុងកម្រិតមត្តេយ្យសិក្សា និងបឋមសិក្សា ដើម្បីធានាថាសិស្សបានចូលរៀន និងជាពិសេសមានបំណិនក្នុងការគិតកម្រិតខ្ពស់ សម្រាប់អនុវត្តកិច្ចការអំណាន និងគណិតវិទ្យាដែលមានលក្ខណៈវែងៗ និងដែលត្រូវការការគិតកម្រិតខ្ពស់។ ក្នុងចំណុចនេះ សាលារៀន និងគ្រូបង្រៀនត្រូវពិនិត្យឡើងវិញ និងអភិវឌ្ឍកិច្ចការ ឬលំហាត់ផ្សេងៗ ដែលបង្កើនកម្រិតពុទ្ធិរបស់សិស្ស តាមកម្រិតនីមួយៗ និង

បញ្ចូលកិច្ចការ ឬលំហាត់ទាំងនោះនៅក្នុងការវាយតម្លៃកម្រិតថ្នាក់រៀន មិនថាជាការវាយតម្លៃតាមដំណាក់ ឬការវាយតម្លៃបញ្ចប់នោះទេ។

- អភិវឌ្ឍ ឬកែលម្អប្រព័ន្ធពិនិត្យតាមដាន និងប្រឹក្សាសាលារៀន ធៀបនឹងស្តង់ដាដែលបានកំណត់ ក្នុងគោលបំណងធ្វើឱ្យមានមូលដ្ឋានគ្រឹះសម្រាប់ភាពជោគជ័យនៅកម្រិតសាលារៀន។
- បន្តលើកកម្ពស់ការបណ្តុះបណ្តាលគ្រូបង្រៀន និងវិធីបង្រៀនផ្សេងៗ ឱ្យស្របគ្នាទៅនឹងក្របខណ្ឌសមត្ថភាពសកលដែលវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាត្រូវបានលើកកម្ពស់នៅក្នុងការបង្រៀន និងរៀន និងបន្តគាំទ្រដល់សាលារៀនដែលជួបការលំបាក។
- បណ្តុះបណ្តាល និងប្រើប្រាស់គ្រូបង្រៀនដែលលើស ដើម្បីផ្តល់ការបង្រៀនបន្ថែមដល់សិស្សដែលងាយរងគ្រោះ និងសិស្សខ្សោយ ដើម្បីកាត់បន្ថយអត្រារៀនត្រួតថ្នាក់។
- លើកតម្កើងការបង្រៀន និងរៀនដោយផ្អែកលើលទ្ធផលសិក្សា និងកញ្ចប់សមត្ថភាព នៅក្នុងបណ្តាមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូទាំងអស់ និងនៅកម្រិតសាលារៀន។
- បង្កើនឱកាសរៀននៅក្នុង និងក្រៅថ្នាក់រៀន ដោយបញ្ចូលបន្ថែមកិច្ចការរៀនសូត្រផ្សេងៗទៅក្នុងការបង្រៀន និងរៀន។ កិច្ចការនេះសុទ្ធតែអាចធ្វើបាន និងត្រូវតែធ្វើ ហើយវាមិនត្រូវការចំណាយច្រើននោះទេ។

## ឯកសារយោង


MoEYS. (2016). *Results of grade three student achievement from the national assessment in 2015.* Phnom Penh: MoEYS.

MoEYS. (2017). *Results of grade six student achievement from the national asssessment in 2016.* Phnom Penh: MoEYS.

MoEYS. (2018). *Education in Cambodia: Findings from Cambodia's experience in PISA for Development.* Phnom Penh: MoEYS.

MoEYS. (2018). *K-12 student learning assessment framework.* Phnom Penh: MoEYS.

MoEYS. (2018). *Results of grade 8 student achievement from the national asssessment in 2017.* Phnom Penh: MoEYS.

OECD. (2013). *PISA 2012 Results: What Makes Schools Successful? Resources, Policies and Practices (Volume IV).* OECD Publishing. doi:10.1787/9789264201156-en

OECD. (2016). *PISA 2015 Results (Volume I): Excellence and Equity in Education.* OECD Publishing. doi:10.1787/9789264266490-en

OECD. (2017). PISA 2015 Assessment and Analytical Framework: Science, Reading, Mathematic, Financial Literacy and Collaborative Problem Solving. In *PISA.* OECD Publishing, Paris. doi:http://dx.doi.org/10.1787/9789264281820-en

Schleicher, A. (2018). *World Class: How to build a 21st-century school system.* Paris: OECD Publishing.

UNESCO. (2015). *Student learning assessment.* Bangkok: UNESCO.

Willms, J. (2015). *Educational Prosperity.* Fredericton: The Learning Bar Inc.

World Bank. (2018). *Learning to realize education's promise.* Washington DC: World Bank.

*Policy Brief of Cambodia Education Review*
Issue 2, 2020
*A publication of ERC – Education Research Council*
*This publication is funded by ADB/USESDP Loan No.3427-CAM (COL)*

# Why Cambodia should build Professional Learning Communities (PLC) at all educational establishments?

Bunrith Suon & Sam Sideth Dy

Correspondence Author | Bunrith Suon, Department of Policy | E-mail: rithsb@gmail.com

## Introduction

The purposes of having this Policy Brief is to draw attention to ensure that all players in education sectors have strong knowledge and skills to improve their working results. The intent is to create PLC at all school levels and the teaching training institutions such as Teacher Education Colleges (TEC), National Institute of Education (NIE), Regional Teacher Training Centers (RTTCs) and Provincial Teacher Training Centers (PTTCs) to establish Professional Learning Communities (PLC) by subjects and areas of specializations.

Vision of the Ministry of Education, Youth and Sport is to establish and develop human resources that are of the very highest quality and are ethically sound in order to develop a knowledge-based society within Cambodia as sited in the Education Strategic Plan, 2019-2023. In order to develop such a high quality of human resources responsive to the socio-economic development and labor market needs, quality of teachers and quality of teacher educators with effective school managers and teacher education institution directors is prerequisite to enhance the quality of teaching and learning of all students and teacher trainees at their respective establishments.

Students of the 21st century must be taught by teachers of the 21st century and facilitated and managed by school leaders of the 21st century as science and technology are rapidly flown into society and economy binding us all in which is hard to resist this change. The solution to the unforeseeable knowledge and skills is to enable learning for all in education system and flexible teaching and learning contents adjusting to emerging issues. Hence creation of learning society through development of professional learning communities at school and all education providers is key to enhance capacity of the teachers and staff of education service sector.

Global perspectives on learning management for professional development is to start with building a strong school culture with a learning organizational behavior toward improving school effectiveness (Russell, 2008; Fullan, 2008). People learn from other people, share with other, and together with other create new ideas and solutions to the problems they face (Fullan, 2008). Hence, the opportunity for learning has to be created for all teachers and school administrators to improve their practices and services toward better student's satisfactions and learning outcomes. Professional learning community or sometimes called community of practice has been instrumental to for continuous professional developments in various schools in various countries and Asia, America and Europe (Lam, 2004).

## The Concept

Professional Learning Community (PLC) is widely used to build capacity of teachers and school leaders to manage change and improve capacity of learning and teaching. PLC idea is to facilitate learners to come together in a group—a community—to learn with and learn from each other. The form of the group can be named differently such as lesson study group like in the case of Japan and technical meeting of professionals to discuss issues and seek improvement such as in some developing countries. The group can be named differently and with diversity and flexibility of tasks and responsibilities. What we need to ensure is that we should have a group of educators that meets regularly, shares expertise, and works collaboratively to improve teaching/lecturing skills and the academic performance of teacher trainees/students. The term is also applied to schools or teaching faculty members that use small-group collaboration as a form of continuous professional development. Thus to be consistent with other developed world, PLC should be established in school, teacher education provider and education organization for the benefits of teachers as we consider teaching is not just a job, but a profession that we shall keep teachers to stay professional in all tasks and their daily practices.

### *Why should we establish PLC in Cambodia?*

To serve to two broad purposes: (1) improving the skills and knowledge of educators through collaborative study, expertise exchange, and professional dialogue, and (2) improving the educational aspirations, achievement, and attainment of students through stronger leadership and teaching. PLCs often function as a form of action research as a way to continually question, reevaluate, refine, and improve teaching strategies and knowledge. Meetings are goal-driven exchanges facilitated by educators who have been trained to lead PLCs. Participation in meetings may be entirely voluntary or requirements that all faculty members participate. Facilitators of the PLC are important role players to ensure the PLC run well toward the goals and the learning outcomes.

In schools, action research refers to a wide variety of evaluative, investigative, and analytical research methods designed to diagnose problems or weaknesses—whether organizational, academic, or instructional—and help educators develop practical solutions to address them quickly and efficiently. Action research may also be applied to programs or educational techniques that are not necessarily experiencing any problems, but that educators simply want to learn more about and improve. The general goal is to create a simple, practical, repeatable process of iterative learning, evaluation, and improvement that leads to increasingly better results for schools, teachers, or programs.

## The Context

There are approximately 14,500 schools from pre-schools to upper secondary schools with about 3.3 million enrolling in the 12-year education system taught by roughly 92,300 teachers. Newly trained teachers are around 3,500 per year to be deployed to these schools after their graduation and successfully recruited through standardized system at 16 provincial teacher training centers, 4 regional teacher training centers, 2 teacher education colleges and 1 pre-school teacher training center and 1 national institute of education. Key success of the these education establishments rely heavily on teachers, teacher educators and lecturers as well as the institutional managers and leaders of those establishments.

Global trends and issues require students with 21st century skills and the roles of teachers and educators are to enable students to know how to learn and how to search for sources of information and to wisely utilize the information effectively for their development. The roles of schooling have to be adjusted to the concept of learning organizations in which lifelong learning environment shall be for both personal and professional improvement to better serve the school to achieve it strategic plan

of high quality service recognized by community and society to those who spend a particular number of years at school either at primary or secondary school level.

Having observed to the context of Cambodia despite technical meeting and cluster school systems exist to support professional learning for teachers and school administrators. Lacking of support mechanisms for teachers and other related education personnel for their professional development in terms of having a regular platforms or institutions for them to refer to for their professional development and growth, causing low quality of tasks given by institutional authorities given to them at their respective workplace. Lesson Study concept introduced by the Japanese were introduced in late 2000s and scaled up to various schools in early 2010s with good results under the JICA projects. In line with the movement of building knowledge-based society and enhance quality of teaching a learning group of professionals should be established accordingly.

## How PCL is managed?

In each educational establishment either school or teacher training institution should build a strong learning team for professional growth of all staff. PLC, when effectively operated can reduce misunderstanding and prevent conflicts in the work place as well as dealing with issues and enhance capacity of staff. PLC should be inspired to be established after all members fully understand the concept, usefulness and benefit of having it. The institutional managers and leaders should propose and support staff with same subjects or same grade they teach at school to team up and if the number of the members are too small, they may reach out to other network or nearby school to bind into a group with strong support from the school leader and facilitator to ensure the workplan and agenda for the group meeting.

In PLC, teams are often built around shared roles or responsibilities. For example, the teachers/educators in a particular group may all teach the first year students/trainees or they may all teach science, and these shared attributes allow participants to focus on specific problems and strategies—How do I teach *this* particular student better? How do I teach *this* scientific theory more effectively?—rather than on general educational goals or theories. Teachers, for example, will discuss and reflect on their instructional techniques, lesson designs, and assessment practices, while administrators may address leadership questions, strategies, and issues.

## *Members of PLC*

Given the significant roles of the school directors and school management committee in nurturing school improvement and responsive education to the communities. Organizational learning has been reconceptualized to create learning environment at educational establishments to correct the past errors and ensure best practices through changing behaviors using new insights and knowledge generated from the process of information-gathering and sense-making (Lam, 2004). Hence, all education personnel working at school and at the TTI such as teacher educators/trainers, directors, school leaders and teachers. They can also be members of any other kinds of learning and research for development communities such as professional society or associations and community of practice for their professional support and development beyond their place of work.

Going beyond PLC, we should consider developing of learning society for Cambodia to build stronger relationships among university, teacher education providers, research and consultancy providers and schools are key to enable effective flow of learning among all professionals.
Those professional education societies – as annual gathering and professional development forum with journals and conference proceedings to be produced as achievements from PLC there may be name as follows.

- Professional Society for teachers by area of focus/subject
- Community of Practice for School Directors/TTC Directors

- School director association/council
- Comparative Education Society, Cambodia
- Education Research Society/Community

## Conclusion

PLC is a platform to be created at school and other educational organization to exercise knowledge and skills in group through sharing and learning from one another. Effective PLC requires effective management and facilitation by all members and the school administrators to ensure the professional growth of all members. School directors are reform leaders in building stronger school management system and ensuring the structural flow of communications and learning opportunity. Stronger school culture comprises strong learning community in which teachers and school leaders develop their capacity continuously and create mentoring and coaching system. The PLC cannot be well managed without leadership and constant support of the school management committee as well as the authority oversighting the school.

School improvement strategies cannot neglect establishment of PLC. School effectiveness requires strong school-based management strategies with all members of the school including students and parent-teacher association. Thus, having PLC is to create platform for teachers and school leaders to interact personally and professionally with one another for their self-development for school improvement and PLC shall serve its core mission to encourage teachers and school leaders to learn from and learn with each other to enhance their work capacity for growth in order to support students to achieve their learning needs.

## References

Fullan, M. (2008). Leading professional learning. In Munro, J. H. (Ed.) *Educational leadership: Roundtable viewpoints*. Mc. Graw-Hill. New York.

Lam, Y.L.J. (2004). Factors for differential developments in organizational learning: a case for Hong Kong schools. *International Journal of Educational Development*, 24, 155-166.

Russell, A. L (2008). On learning and systems that facilitate it. In Munro, J.H. (Ed.). *Educational leadership: Roundtable viewpoints*. Mc. Graw-Hill. New York.

ឯកសារសិក្សាគោលនយោបាយសង្ខេប
ការចេញផ្សាយលេខ០១ ឆ្នាំ២០២០
ការបោះពុម្ពផ្សាយរបស់ ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ
ក + ខ - គ × ឃ ÷ Л ∑ ψ ∫ ф Ω ៛ $ ☺
*ការបោះផ្សាយនេះឧបត្ថម្ភដោយគម្រោងហិរញ្ញវត្ថុធនាគារអភិវឌ្ឍន៍អាស៊ី No.3427-CAM (COL)*

# ហេតុអ្វីកម្ពុជាគួរជម្រុញឱ្យមានសហគមន៍សិក្សាវិជ្ជាជីវៈ(PLC) នៅគ្រប់គ្រឹះស្ថានអប់រំ?

សួន ប៊ុនរិទ្ធ និង ឌី សមស៊ីដេត

ទំនាក់ទំនងអ្នកនិពន្ធ | សួន ប៊ុនរិទ្ធ | អ៊ីម៉ែល៖ rithsb@gmail.com

## ផ្ដើមសេចក្ដី

ចេតនានៃឯកសារគោលនយោបាយសង្ខេបនេះ គឺទាក់ទាញចំណាប់អារម្មណ៍ ដើម្បីជានាថាអ្នកមានភារកិច្ចគន្លឹះទាំងអស់នៅក្នុងវិស័យអប់រំមានចំណេះដឹងខ្ពស់ និងជំនាញរឹងមាំក្នុងការបង្កើនលទ្ធផលការងារឱ្យកាន់តែប្រសើរឡើង។ គោលបំណងសំខាន់គឺបង្កើតឱ្យមាន "**សហគមន៍សិក្សាវិជ្ជាជីវៈ**(PLC)" តាមមុខវិជ្ជា និងតាមវិស័យជំនាញ នៅគ្រប់កម្រិតសាលារៀន និងស្ថាប័នបណ្ដុះបណ្ដាលគ្រូបង្រៀន រួមមានវិទ្យាស្ថានគរុកោសល្យ(TEC) វិទ្យាស្ថានជាតិអប់រំ(NIE) មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ(RTTCs) និងសាលាគរុកោសល្យ និងវិក្រឹតការខេត្ត-ក្រុង(PTTCs) ជាដើម។

ចក្ខុវិស័យនៃក្រសួងអប់រំយុវជន និងកីឡា គឺកសាង និងអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពខ្ពស់ និងគុណធម៌ប្រសើរបំផុត ដើម្បីកសាងសង្គមកម្ពុជាឱ្យរីកចម្រើនផ្អែកលើចំណេះដឹងជាមូលដ្ឋាន ដូចមានចែងក្នុងផែនការយុទ្ធសាស្ត្រអប់រំ ឆ្នាំ២០១៩-២០២៣។ ដើម្បីអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាពខ្ពស់សម្រាប់ឆ្លើយតបទៅនឹងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងតម្រូវការទីផ្សារការងារ គុណភាពគ្រូ និងគុណភាពអ្នកបណ្ដុះបណ្ដាលគ្រូ ព្រមទាំងគណៈគ្រប់គ្រងសាលា និងនាយកគ្រឹះស្ថានបណ្ដុះបណ្ដាលគ្រូ ចាំបាច់ត្រូវបង្កើនប្រសិទ្ធិភាព និងគុណភាពនៃការរៀន និងការបង្រៀនសម្រាប់និស្សិត និងគរុសិស្សទាំងអស់ តាមបណ្ដាគ្រឹះស្ថានអប់រំនីមួយៗ។

គរុសិស្ស-និស្សិតនៃសតវត្សរ៍ទី២១ គួរត្រូវបានបង្រៀនដោយគ្រូឧទ្ទេសនៃសតវត្សរ៍ទី២១ ហើយត្រូវដឹកនាំ និងសម្របសម្រួល ដោយនាយកសាលាសតវត្សរ៍ទី២១ដែរ។ សន្ទុះវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាបានហក់ចូលយ៉ាងលឿនក្នុងសង្គម និងសេដ្ឋកិច្ច ហើយបានចងភ្ជាប់យើងទាំងអស់គ្នា ដែលធ្វើឱ្យពិបាកទប់ទល់នឹងការផ្លាស់ប្ដូរដ៏គំហុកនេះ។ ដំណោះស្រាយចំពោះមុខ ទៅនឹងជំនាញ និងវិជ្ជាដែលមិនអាចទាយទុកមុនបាន គឺជួយធ្វើឱ្យមានការរៀនសម្រាប់គ្រប់គ្នានៅក្នុងប្រព័ន្ធអប់រំទាំងអស់ ហើយខ្លឹមសារគោលនៃការរៀន និងបង្រៀន អាចបត់បែនផ្លាស់ប្ដូរបានតាមកាលៈទេសៈតម្រូវតាមបញ្ហាដែលកំពុងកើតឡើង។ ដូច្នេះការបង្កើតសហគមន៍សិក្សាតាមរយៈការអភិវឌ្ឍសហគមន៍សិក្សាវិជ្ជាជីវៈជំនាញនៅតាមសាលា និងគ្រឹះស្ថានផ្ដល់សេវាអប់រំ គឺជាគន្លឹះក្នុងការបង្កើនសមត្ថភាពគ្រូបង្រៀន និងបុគ្គលិកអប់រំ។

ទស្សនវិស័យសកលស្តីពីការគ្រប់គ្រងការសិក្សា សម្រាប់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈ គឺចាប់ផ្តើមពីការកសាងវប្បធម៌សាលារៀនរឹងមាំសិន រួមជាមួយនឹងឥរិយាបថនៃការសិក្សា ឆ្ពោះទៅបង្កើនប្រសិទ្ធភាពសាលារៀន (Russell, 2008; Fullan, 2008)។ មនុស្សជាតិរៀនសូត្រពីមនុស្សជាតិដទៃទៀត និងចែករំលែកជាមួយគ្នា ហើយជាមួយអ្នកដទៃទៀត ចាប់ផ្តើមបង្កើតគំនិតថ្មី និងដំណោះស្រាយផ្សេងៗ ចំពោះបញ្ហាដែលពួកគេកំពុងប្រឈម (Fullan, 2008)។ ដូច្នេះ ឱកាសសម្រាប់ការសិក្សារៀនសូត្រ ត្រូវតែបង្កើតឡើងសម្រាប់គ្រូនិងអ្នកគ្រប់គ្រងសាលាទាំងអស់ដើម្បីកែលម្អការអនុវត្ត និងសេវាកម្ម ឆ្ពោះទៅរកការពេញចិត្តនៃសិស្សនុសិស្ស ហើយលទ្ធផលនៃការសិក្សារបស់ពួកគេកាន់តែប្រសើរឡើង។ សហគមន៍សិក្សាវិជ្ជាជីវៈ ឬជួនកាលហៅថា សហគមន៍អនុវត្តល្អ បានក្លាយជាឧបករណ៍ចាំបាច់ក្នុងការបន្តជួយដល់ការអភិវឌ្ឍជំនាញវិជ្ជាជីវៈនៅតាមសាលានានា នៅប្រទេសជាច្រើន ក្នុងទ្វីបអាស៊ី អាមេរិក និងអឺរ៉ុប(Lam, 2004)។

## ទស្សនទាន

សហគមន៍សិក្សាវិជ្ជាជីវៈ(PLC) ត្រូវបានអនុវត្តជាទូទៅដើម្បីកសាងសមត្ថភាពគ្រូ និងគណៈគ្រប់គ្រងសាលាក្នុងការគ្រប់គ្រងការផ្លាស់ប្តូរ និងបង្កើនសមត្ថភាពរៀន និងបង្រៀន។ គំនិតគោល នៃភីអិលស៊ី គឺជួយសម្របសម្រួលអ្នកសិក្សាឱ្យរួមគ្នាបង្កើតជាក្រុមស្វ័យសិក្សា -សហគមន៍ស្វ័យសិក្សា- ដើម្បីរៀនជាមួយគ្នា ហើយរៀនពីគ្នាទៅវិញទៅមក។ គេអាចឱ្យឈ្មោះក្រុមខុសៗគ្នា ដូចជាករណីជប៉ុនក្រុមសិក្សាមេរៀន និងការប្រជុំបច្ចេកទេសនៃអ្នកជំនាញ ដើម្បីពិភាក្សាអំពីបញ្ហា និងធ្វើការកែលម្អ ដូចបានអនុវត្តនៅបណ្តាប្រទេសកំពុងអភិវឌ្ឍ។ ក្រុមនេះអាចមានឈ្មោះខុសគ្នា អាចមានសមាជិកចម្រុះ ភារកិច្ច និងការទទួលខុសត្រូវ អាចមានភាពបត់បែនតាមស្ថានភាព។ អ្វីដែលយើងចង់ធានាឱ្យមានភាពជាប់លាប់ គឺថាយើងត្រូវតែមានក្រុមអ្នកអប់រំ មកជួបជុំនុំគ្នាទៀងទាត់ ចែករំលែកចំណេះជំនាញ និងសហការគ្នា រួមគ្នាអភិវឌ្ឍវិធីសាស្ត្របង្រៀន និងការសិក្សាអនុវត្តរបស់គរុសិស្ស-និស្សិត។ គេគួរអនុវត្តដូចគ្នាដែរ នៅតាមសាលារៀន ឬសាស្ត្រាចារ្យមហាវិទ្យាល័យ ដែលចងជាក្រុមតូចៗ សហការគ្នាដើម្បីបន្តអភិវឌ្ឍជំនាញវិជ្ជាជីវៈនៃក្រុមខ្លួន។ ដូច្នេះដើម្បីដើរឱ្យទាន់ និងស្របតាមប្រទេសអភិវឌ្ឍន៍ដទៃទៀត ភីអិលស៊ី គួរតែបង្កើតឡើងនៅតាមសាលារៀន គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងស្ថាប័នអប់រំ ដើម្បីជាគុណប្រយោជន៍ដល់គ្រូបង្រៀន។ យើងយល់ច្បាស់ហើយថា ការបង្រៀនមិនមែនគ្រាន់តែជាអាជីពយកប្រាក់ខែប៉ុណ្ណោះទេ ប៉ុន្តែគឺជាជំនាញវិជ្ជាជីវៈមួយបែប ហើយយើងត្រូវផ្តល់លទ្ធភាពឱ្យគ្រូបង្រៀនស្ថិតនៅក្នុងជំនាញវិជ្ជាជីវៈ លើគ្រប់ភារកិច្ច និងការអនុវត្តប្រចាំថ្ងៃរបស់ពួកគាត់។

## ហេតុអ្វីយើងគួរបង្កើត ភីអិលស៊ី នៅកម្ពុជា?

ដើម្បីបម្រើដល់គោលបំណងធំៗពីរគឺ៖ (១) ធ្វើឱ្យប្រសើរឡើងនូវចំណេះដឹង និងជំនាញនៃអ្នកអប់រំ តាមរយៈការសិក្សាជាមួយគ្នា ការផ្លាស់ប្តូរបទពិសោធជំនាញ និងកិច្ចពិភាក្សាវិជ្ជាជីវៈ និង (២) លើកកម្ពស់បំណងប្រាថ្នាក្នុងការអប់រំ សមិទ្ធិផល និងលទ្ធផលសិក្សារបស់សិស្សតាមរយៈការដឹកនាំល្អ និងការបង្រៀនល្អ។ ភីអិលស៊ី ច្រើនដំណើរការក្នុងទម្រង់នៃការស្រាវជ្រាវសកម្មភាព តាមបែបវិធានសំណួរជាប្រចាំ វាយតម្លៃឡើងវិញ កែលម្អឱ្យប្រសើរឡើង និងលើកកម្ពស់ចំណេះដឹង និងយុទ្ធសាស្ត្របង្រៀន។ ការផ្លាស់ប្តូរបទពិសោធ គឺជាគោលដៅនាំមុខ ក្នុងការជួបជុំ ដែលនឹងសម្របសម្រួលដោយអ្នកអប់រំម្នាក់ ដែលបានទទួលការបណ្តុះបណ្តាលឱ្យដឹកនាំភីអិលស៊ី។ ការចូលរួមជួបជុំគ្នាធ្វើស្វ័យសិក្សា អាចជាការស្ម័គ្រចិត្តទាំងស្រុង ឬក៏ជាលក្ខខណ្ឌដែលស្ថាប័នអប់រំ តម្រូវឱ្យអ្នកគ្រូ-លោកគ្រូទាំងអស់ចូលរួម។ អ្នកសម្របសម្រួលរបស់ភីអិលស៊ី ដើរតួយ៉ាងសំខាន់ដើម្បីធានាថាភីអិលស៊ី អាចដំណើរការទៅបានល្អ សម្រេចបានតាមគោលដៅ និងលទ្ធផលនៃការសិក្សា។

នៅក្នុងសាលារៀន ការស្រាវជ្រាវសកម្មភាព សំដៅដល់វិធីវង្វាយតម្លៃច្រើនបែបផ្សេងៗគ្នា វិធីអង្កេត និងវិធីស្រាវជ្រាវវិភាគ ដែលបានរចនាឡើងដើម្បីធ្វើរោគវិនិច្ឆ័យលើបញ្ហា ឬចំណុចខ្សោយ បើទោះជាពិនិត្យលើរចនាសម្ព័ន្ធ ការសិក្សារៀនសូត្រ ឬការបង្ហាត់បង្រៀន គឺដើម្បីជួយឱ្យអ្នកអប់រំ អាចរិះរកវិធីដោះស្រាយសមស្រប ឆ្លើយតបបានឆាប់រហ័ស និងមានប្រសិទ្ធភាព។ ការស្រាវជ្រាវសកម្មភាព ក៏អាចអនុវត្តបានលើកម្មវិធី ឬបច្ចេកទេសអប់រំ ដែលមិនជួបបញ្ហាជាឧបសគ្គ គ្រាន់តែអ្នកជំនាញអប់រំ ចង់សិក្សាស្វែងយល់បន្ថែម និងជួយកែលម្អឱ្យប្រសើរឡើង។ គោលវិធីជាទូទៅគឺបង្កើតឱ្យមានការអនុវត្តដែលងាយស្រួល វដ្តនៃដំណើរការរៀនធ្វើម្តងហើយម្តងទៀត វង្វាយតម្លៃ និងការវិវត្តឆ្ពោះទៅរកលទ្ធផលឱ្យកាន់តែល្អប្រសើរសម្រាប់សាលារៀន គ្រូបង្រៀន ឬកម្មវិធី។

## បរិបទ

មានសាលារៀនប្រមាណ១៤.៥០០ រាប់ទាំងពីសាលាមត្តេយ្យ ដល់វិទ្យាល័យ ដែលមានសិស្សានុសិស្សប្រហែល ៣.៣លាននាក់បានចុះឈ្មោះចូលរៀន (នៅក្នុងប្រព័ន្ធអប់រំរយៈពេល ១២ឆ្នាំ) ដែលបង្រៀនដោយអ្នកគ្រូ-លោកគ្រូប្រមាណ ៩២.៣០០នាក់។ គ្រូដែលទើបទទួលបានការបណ្តុះបណ្តាលថ្មីមានចំនួនប្រហែល ៣.៥០០រូប ក្នុងមួយឆ្នាំ ដែលនឹងត្រូវបញ្ជូនទៅសាលារៀនទាំងនេះ បន្ទាប់ពីបានបញ្ចប់ការសិក្សាដោយជោគជ័យ ហើយបានជ្រើសរើសស្របតាមរយៈប្រព័ន្ធស្តង់ដារ នៃសាលាគរុកោសល្យ និងវិក្រឹតការខេត្ត-ក្រុងទាំង១៦, មជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ចំនួន ៤, វិទ្យាស្ថានគរុកោសល្យ ចំនួន២, សាលាគរុកោសល្យ មត្តេយ្យមជ្ឈិម ចំនួន១, និងវិទ្យាស្ថានជាតិអប់រំ ចំនួន១។ គន្លឹះជោគជ័យ នៃគ្រឹះស្ថានអប់រំទាំងនេះ ពឹងផ្អែកទាំងស្រុងទៅលើគ្រូបង្រៀន, គ្រូឧទ្ទេស និងសាស្ត្រាចារ្យ ក៏ដូចជាអ្នកគ្រប់គ្រង និងដឹកនាំ របស់គ្រឹះស្ថានទាំងនោះ។

និន្នាការសាកលលោក និងបញ្ហាដែលកំពុងកើតឡើង តម្រូវឱ្យសិស្សានុសិស្សមានជំនាញសតវត្សទី២១ ហើយតួនាទីរបស់គ្រូ និងអ្នកអប់រំ គឺជួយឱ្យសិស្សដឹងពីរបៀបរៀន និងវិធីស្វែងរកប្រភពព័ត៌មាន ហើយប្រើប្រាស់ព័ត៌មានដោយភាពវាងវៃ និងមានប្រសិទ្ធភាពដើម្បីវឌ្ឍនភាពពួកគេ។ តួនាទីសាលារៀន ត្រូវតែកែសម្រួលឱ្យស្របទៅនឹងរចនាសម្ព័ន្ធនៃការសិក្សា ដោយបង្កើនបរិយាកាសរៀនពេញមួយជីវិត ដើម្បីជួយអភិវឌ្ឍទាំងមុខវិជ្ជាជីវៈ និងជីវិតផ្ទាល់ខ្លួន។ ដើម្បីជួយសាលារៀនឱ្យសម្រេចបានគោលបំណងខាងលើ យើងត្រូវការបង្កើតយុទ្ធសាស្ត្រ នៃការទទួលស្គាល់គុណភាព និងការផ្តល់រង្វាន់លើកទឹកចិត្ត ដោយបានទទួលស្គាល់ពីសហគមន៍ និងសង្គម ជូនបុគ្គលឆ្នើម ដែលបានចំណាយពេលវេលាច្រើនឆ្នាំ(តាមការកំណត់) ទាំងនៅកម្រិតបឋមសិក្សា ឬមធ្យមសិក្សា។

សង្កេតលើបរិបទនៃប្រទេសកម្ពុជា ទោះបីមានការប្រជុំបច្ចេកទេស និងប្រព័ន្ធសាលាកម្រង ដើម្បីជួយគាំទ្រដល់ការសិក្សាអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន និងបុគ្គលិករដ្ឋបាលសាលាយ៉ាងណាក្តី ក៏នៅមានកង្វះខាតយន្តការគាំទ្រគ្រូបង្រៀន និងបុគ្គលិកសិក្សា ក្នុងការអភិវឌ្ឍវិជ្ជាជីវៈរបស់ពួកគាត់ ក្នុងន័យថាមិនមានវេទិកា ឬស្ថាប័នណាមួយ សម្រាប់ពួកគាត់ពឹងផ្អែកក្នុងការអភិវឌ្ឍវិជ្ជាជីវៈជំនាញរបស់ពួកគាត់ ដែលនេះជាមូលហេតុនាំឱ្យការងារនៅតាមបណ្តាស្ថាប័នពួកគាត់ មានគុណភាពអន់ថយ។ បញ្ញត្តិសិក្សាមេរៀន ដែលបានដាក់ឱ្យប្រើប្រាស់ដោយអង្គការជប៉ុន កាលពីចុងទសវត្សរ៍ឆ្នាំ២០០០ និងពង្រីកវិសាលភាពនៃការអនុវត្តដល់សាលារៀនផ្សេងៗទៀតនៅដើមទសវត្សរ៍ឆ្នាំ២០១០ ទទួលបានលទ្ធផលល្អ នៅក្នុងគម្រោងអង្គការ JICA។ ស្របតាមចលនានៃការកសាងសង្គមកម្ពុជាឱ្យក្លាយជាសង្គមរីកចម្រើនផ្អែកលើចំណេះដឹងជាមូលដ្ឋាន និងការបង្កើនគុណភាពបង្រៀន ក្រុមអ្នកសិក្សាជំនាញវិជ្ជាជីវៈគួរត្រូវបង្កើតឡើងស្របតាមនោះ។

## តើត្រូវគ្រប់គ្រង ភីអិលស៊ី បែបម៉េច?

នៅតាមគ្រឹះស្ថានអប់រំនីមួយៗ ទោះជាសាលារៀន ឬស្ថាប័នបណ្តុះបណ្តាលគ្រូ ត្រូវតែបង្កើតក្រុមស្វ័យសិក្សាដ៏រឹងមាំមួយ សម្រាប់ការរីកចម្រើនវិជ្ជាជីវៈនៃបុគ្គលិកទាំងអស់។ នៅពេលភីអិលស៊ីដំណើរការប្រកបដោយប្រសិទ្ធភាព គឺអាចជួយកាត់បន្ថយភាពមិនយល់គ្នា និងទប់ស្កាត់ទំនាស់ផ្សេងៗនៅកន្លែងធ្វើការ ក៏ដូចជាការដោះស្រាយបញ្ហា និងការបង្កើនសមត្ថភាពបុគ្គលិក។ ភីអិលស៊ី គួរត្រូវបានបំផុសគំនិតឱ្យបង្កើតឡើង បន្ទាប់ពីសមាជិកទាំងអស់យល់ច្បាស់ពីទស្សន និងអត្ថប្រយោជន៍របស់ភីអិលស៊ី។ អ្នកគ្រប់គ្រងស្ថាប័ន និងថ្នាក់ដឹកនាំ គួរស្នើសុំការគាំទ្រគ្រូដែលបង្រៀនមុខវិជ្ជាដូចគ្នា ឬកម្រិតថ្នាក់ដូចគ្នាឱ្យបង្កើតជាក្រុមស្វ័យសិក្សា ហើយប្រសិនបើចំនួនសមាជិកមានគ្នាតិចពេក ពួកកាត់អាចចងបណ្តាញជាមួយសាលារៀនជិតខាង ដើម្បីភ្ជាប់ជាក្រុមស្វ័យសិក្សា ហើយត្រូវមានការគាំទ្រខ្លាំងក្លាពីថ្នាក់ដឹកនាំសាលា ព្រមទាំងអ្នកសម្របសម្រួល ត្រូវជានាឱ្យបាននូវផែនការការងារ និងរបៀបវារៈសម្រាប់ការប្រជុំក្រុមស្វ័យសិក្សា។

ការអនុវត្តនៃភីអិលស៊ី ជាធម្មតាក្រុមស្វ័យសិក្សា ត្រូវចែករំលែកនូវតួនាទី និងទទួលខុសត្រូវរួមគ្នា។ ឧទាហរណ៍៖ គ្រូបង្រៀនក្នុងក្រុមជាមួយ អាចបង្រៀននិស្សិត-គរុសិស្សឆ្នាំដំបូង ឬពួកគាត់អាចបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រ ហើយការណ៍ដែលបង្កើតក្រុមតាមជំនាញនេះ ជួយឱ្យគ្រូៗ អាចផ្តោតលើបញ្ហា និងយុទ្ធវិធីជាក់លាក់ណាមួយ ដូចជាថា៖ តើខ្ញុំត្រូវបង្រៀនសិស្សម្នាក់នេះបែបណាទើបល្អ? តើខ្ញុំបង្រៀនទ្រឹស្តីវិទ្យាសាស្ត្រនេះ បែបណាឱ្យងាយយល់? ការណ៍នេះវាប្រសើរជាងបង្រៀន ពីគោលបំណង ឬទ្រឹស្តីអប់រំទូទៅ។ ជាទូទៅ គ្រូបង្រៀនពិភាក្សា និងឆ្លុះបញ្ចាំងពីបច្ចេកទេសនៃការបង្រៀន, ការរចនាមេរៀន និងការអនុវត្តវង្វាយតម្លៃ ខណៈពេលដែលបុគ្គលិករដ្ឋបាល គិតពីសំណួរដែលទាក់ទងដល់ភាពជាអ្នកដឹកនាំ, ផែនការយុទ្ធសាស្ត្រ និងបញ្ហានានា។

## សមាជិកនៃភីអិលស៊ី

នាយកសាលា និងគណៈគ្រប់គ្រងសាលារៀន មានតួនាទីសំខាន់ណាស់ ក្នុងការធ្វើឱ្យសាលាមានភាពល្អប្រសើរ និងមានការអប់រំដែលឆ្លើយតបទៅនឹងសហគមន៍។ រចនាសម្ព័ន្ធនៃការសិក្សា ត្រូវបានរៀបចំឡើងវិញ ដើម្បីកសាងបរិយាកាសសិក្សានៅតាមគ្រឹះស្ថានអប់រំ ក្នុងគោលដៅកែកំហុសពីអតីត និងធានានូវការអនុវត្តល្អ តាមរយៈការផ្លាស់ប្តូរអាកប្បកិរិយាដោយប្រើញាណទស្សន និងចំណេះដឹងថ្មីៗ ដែលបានមកពីដំណើរការនៃការប្រមូលព័ត៌មាន និងអព្ភន្តរញ្ញាណ (Lam, 2004)។ ហេតុនេះ សមាជិកភីអិលស៊ី អាចជាបុគ្គលិកអប់រំទាំងអស់ដែលធ្វើការនៅសាលារៀន និងនៅតាមគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ ដូចជាអ្នកអប់រំ ឬគ្រូឧទ្ទេស នាយកសាលា និងបុគ្គលិកសិក្សាជាដើម។ ពួកគាត់ក៏អាចជាសមាជិកនៃក្រុមស្វ័យសិក្សា ឬសហគមន៍អភិវឌ្ឍស្រាវជ្រាវផ្សេងទៀត ដូចជាសមាគមអាជីពវិជ្ជាជីវៈ ឬក៏សហគមន៍ឧត្តមានុវត្តន៍នានាសម្រាប់គាំទ្រ និងអភិវឌ្ឍជំនាញវិជ្ជាជីវៈ ផ្សេងអំពីស្ថាប័នការងាររបស់ពួកគាត់។

លើសអំពីភីអិលស៊ីនេះទៀត យើងគួរពិចារណាបង្កើតសមាគមសិក្សាសម្រាប់ប្រទេសកម្ពុជា ដែលអាចកសាងទំនាក់ទំនងរឹងមាំក្នុងចំណោមសាកលវិទ្យាល័យ, គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ, ស្ថាប័នស្រាវជ្រាវ និងប្រឹក្សាយោបល់។ល។ ដែលទាំងនេះគឺជាគន្លឹះដ៏ស័ក្តសិទ្ធិ នាំឱ្យមានលំហូរនៃការសិក្សា ក្នុងចំណោមអ្នកជំនាញវិជ្ជាជីវៈគ្រប់រូប។

សមាគមអប់រំវិជ្ជាជីវៈទាំងនោះ អាចរៀបចំការជួបជុំប្រចាំឆ្នាំ ឬវេទិកាអភិវឌ្ឍវិជ្ជាជីវៈ ឬកាលិកបត្រ និងសន្និសីទ ដែលអាចជាផ្នែកមួយនៃ ភីអិលស៊ី ដូចមានឈ្មោះខាងក្រោម៖

- សមាគមវិជ្ជាជីវៈសម្រាប់គ្រូតាមមុខវិជ្ជាឯកទេស ឬប្រធានបទ
- សហគមន៍ឧត្តមានុវត្តន៍ សម្រាប់នាយកសាលា ឬនាយកវិទ្យាស្ថាន
- សមាគម ឬក្រុមប្រឹក្សានាយកសាលា
- សមាគមអប់រំប្រៀបធៀបកម្ពុជា
- សមាគមស្រាវជ្រាវអប់រំ

## សេចក្តីសន្និដ្ឋាន

ភីអិលស៊ី គឺជាវេទិកាមួយដែលត្រូវបង្កើតឡើងនៅសាលារៀន និងគ្រឹះស្ថានអប់រំនានា ដើម្បីធ្វើការអនុវត្តចំណេះដឹង និងជំនាញ ជាក្រុមស្វ័យសិក្សា តាមរយៈការចែករំលែក និងរៀនពីគ្នាទៅវិញទៅមក។ ភីអិលស៊ី ដែលមានប្រសិទ្ធភាពទាមទារឱ្យមានការគ្រប់គ្រង និងសម្របសម្រួល ប្រកបដោយប្រសិទ្ធភាព អំពីសមាជិកគ្រប់រូប និងរដ្ឋបាលសាលាគ្រប់រូប ដើម្បីជានាឱ្យបាននូវការអភិវឌ្ឍវិជ្ជាជីវៈ នៃសមាជិកទាំងអស់។ នាយកសាលា គឺជាអ្នកដឹកនាំកំណែទម្រង់ក្នុងការកសាងប្រព័ន្ធគ្រប់គ្រងសាលារៀនដ៏រឹងមាំ និងធានាឱ្យបាននូវលំហូរនៃការទំនាក់ទំនង និងឱកាសសិក្សា។ វប្បធម៌សាលារៀនរឹងមាំ គឺសហគមន៍សិក្សារៀនសូត្រខ្លាំងដែលគ្រូ និងថ្នាក់ដឹកនាំសាលា អភិវឌ្ឍសមត្ថភាពរបស់ខ្លួនជាប្រចាំ និងបង្កើតប្រព័ន្ធមគ្គុទ្ទេស និងបង្ហាត់បង្ហាញ។ ភីអិលស៊ី មិនអាចគ្រប់គ្រងបានល្អដោយគ្មានការដឹកនាំ និងការគាំទ្រជាប្រចាំពីគណៈគ្រប់គ្រងសាលា ក៏ដូចជាអាជ្ញាធរដែលត្រួតពិនិត្យលើសាលារៀននោះ។

យុទ្ធសាស្ត្រកែលម្អឱ្យសាលារៀនបានប្រសើរឡើង មិនអាចមិនយកចិត្តទុកដាក់ក្នុងការបង្កើតភីអិលស៊ីនោះទេ។ ប្រសិទ្ធភាពសាលារៀន តម្រូវឱ្យមានយុទ្ធសាស្ត្រគ្រប់គ្រងសាលារៀនរឹងមាំជាមួយសមាជិកសាលារៀនទាំងអស់ រួមទាំងសិស្សានុសិស្ស, គ្រូបង្រៀន និងមាតាបិតា។ ដូច្នេះភីអិលស៊ី គឺជាវេទិកាសម្រាប់គ្រូ និងថ្នាក់ដឹកនាំសាលា ធ្វើអន្តរកម្មដោយផ្ទាល់ខ្លួន និងបែបអាជីព ជាមួយគ្នាទៅវិញទៅមក ក្នុងការអភិវឌ្ឍខ្លួនឯងផង និងការកែលំអសាលារៀនឱ្យកាន់តែប្រសើរផង។ ហេតុនេះ ភីអិលស៊ី បានបំពេញបេសកកម្មស្នូលរបស់ខ្លួន គឺលើកទឹកចិត្តដល់គ្រូ និងថ្នាក់ដឹកនាំសាលា ឱ្យរៀនជាមួយគ្នា ហើយរៀនពីគ្នាទៅវិញទៅមក ក្នុងបំណងបង្កើនសមត្ថភាពការងាររបស់ពួកគាត់ និងដើម្បីជួយគាំទ្រដល់និស្សិត-គរុសិស្ស សម្រេចបានសមិទ្ធផល ក្នុងការសិក្សាដែលខ្លួនចង់បាន។

## ឯកសារយោង

Fullan, M. (2008). Leading professional learning. In Munro, J. H. (Ed.) *Educational leadership: Roundtable viewpoints*. Mc. Graw-Hill. New York.

Lam, Y.L.J. (2004). Factors for differential developments in organizational learning: a case for Hong Kong schools. *International Journal of Educational Development*, 24, 155-166.

Russell, A. L (2008). On learning and systems that facilitate it. In Munro, J.H. (Ed.). *Educational leadership: Roundtable viewpoints*. Mc. Graw-Hill. New York.

*Policy Brief of Cambodia Education Review*
Issue 2, 2018
*A publication of – ERC*
*Education Research Council*

*This publication is funded by ADB Project 47136-003*

# Planning, Financing and Implementing Lifelong Learning: Quality Education-related Sustainable Development Goals in Cambodia

Soth Sok[1], Peou Vanna[2] and Sok Serey[3]

[1] Faculty of Education, Royal University of Phnom Penh, [2] DVV International and [3] Research Office, Royal University of Phnom Penh
Correspondent Author | Sok Serey, Research Office, Royal University of Phnom Penh | E-mail: sok.serey@rupp.edu.kh

**Key Messages**

- Lifelong Learning is a new concept and educational journey adopted by Cambodia so the country can accomplish its sustainable development goals (SDGs) by 2030. Lifelong Learning consists not just of non-formal education but of all formal, non-formal and informal education.
- In 2016, the Ministry of Education, Youth and Sport (MoEYS) invested US $764 million in Lifelong Learning. This figure is 76.1% of the total annual educational budget allocated to help all Cambodians achieve nine years of basic education. 48.3% of this was allocated to primary schools, 18.7% to lower secondary schools and 9.1% to pre-schools. Upper secondary schools and higher education received proportions of 9.2% each. While non-formal education is currently believed to contribute a large pool of activities to support Lifelong Learning outside school, only 2.9% (or $US 22.16 million) of the total annual budget was allocated to this sector in 2016.
- Bilateral, multilateral and international organisations have funded MoEYS activities and local non-government organisations (NGOs) to help the educational sector meet the country's millennium development goals (MDGs) and SDGs. The Lifelong Learning programme will improve if the government of Cambodia allocates extra money for activities beyond those currently available for non-formal education.

## Lifelong Learning in the Cambodian Education System

The concept of Lifelong Learning remains very new to government agencies and non-government organisations (NGOs) in Cambodia. As a result, only a few activities have been undertaken that contribute to this concept. Lifelong Learning is a fundamental goal of recent education policies in Cambodia and it is often advocated as a way to accomplish socioeconomic development and as a tool for promoting a knowledge-based society. The increasing significance of Lifelong Learning in both national and international policy results in the need to place it and its implications under close and critical scrutiny. When using the concept of Lifelong Learning, it is important to be aware of the responsibilities of managing, delivering and supporting Lifelong Learning with opportunities to develop our own analysis and practice in what is a constantly changing economic, social, technological and policy environment.[1] The Former Executive Director of the NGO Education Partnership of Cambodia (NEP) is one of the most prominent and experienced civil society actors in the education sector. He has provided a very brief overview about how the concept of Lifelong Learning has been introduced in Cambodia:

> *In Europe, Lifelong Learning has been introduced for a long time in countries such as Germany. People there also learn at home, in public spaces and at the office. They like reading. Lifelong Learning is a new concept in Cambodia and it was first known when SDGs were introduced. Before 2015, Lifelong Learning was not*

[1] Vice-rector in charge of Research, Royal University of Phnom Penh.

> *discussed or talked about in Cambodia and non-formal education was very popular. Back in 2015, at the SDG conference in Inchon, South Korea, people started to talk about Lifelong Learning. There have been, so far, very few NGOs working on Lifelong Learning, for example DVV.*[2]

In 2010, officials from the Ministry of Education, Youth and Sport (MoEYS) were sent to receive training on Lifelong Learning in Germany, Belgium and the Netherlands. After the training, the Cambodian delegates informed the Minister of MoEYS about Lifelong Learning; however, no action was taken at that time. In October 2017, a delegate from MoEYS was again sent to undertake training on Lifelong Learning in Vietnam. In November 2017, MoEYS organised the first workshop with support from UNESCO and DVV, who initiated the development of a policy on Lifelong Learning in Cambodia. A policy on Lifelong Learning has now been drafted and is waiting for endorsement by the Council of Ministers.[3] A joint High-Level Meeting[4] was called by the Minister of MoEYS, HE Dr Hang Chuon Naron, on 17 November 2017 at the Sofitel Hotel in Phnom Penh, which was the first step towards a Lifelong Learning Policy in Cambodia. The meeting gathered representatives of different ministries, the UNESCO Institute for Lifelong Learning, SEAMEO CELLL and DVV International with the aim of finding a shared understanding of Lifelong Learning and its meaning both internationally and in the Cambodian setting in order to prepare for its translation into Cambodia's national legal framework. The Director of the Department of Non-Formal Education, MoEYS added that:

> *The policy has been developed with strong commitment and support from UNESCO, SEAMEO CELLL, DVV and other national and international organisations working to support the education sector in Cambodia. There are some problems which may constrain the implementation of Lifelong Learning; they include: curriculum, the strategic plan and M&E mechanisms to monitor the strategic plan.*[5]

According to the Phnom Penh-based Chief of Education for UNESCO, "Lifelong Learning is a need of Cambodia. The concept was introduced in 1972 but it is very new to Cambodia. As I am a Hindu… we need to learn the Hindu bible from birth to death. Learning can take place all the time."[6] The education system of Cambodia includes formal, non-formal and informal education and Lifelong Learning is part of non-formal, informal and formal education types. The former Executive Director of the NGO Education Partnership of Cambodia (NEP) explains that Lifelong Learning is more than just non-formal education: all formal, non-formal and informal education contribute to Lifelong Learning. Facilities can help to improve the access of local communities to skills and knowledge. Lifelong Learning can be best implemented when facilities are well equipped. Each community has its own needs and demands, so community-based learning centre should conduct skills and needs assessments in order to identify local needs.[7] The Director of the Department of Non-Formal Education, MoEYS identified issues with current understandings of Lifelong Learning, stating:

> *Non-formal education is a part of Lifelong Learning but we have confusion. Some key actors claim that that non-formal education was an old model and Lifelong Learning should replace it. Non-formal education should not work anymore after the adaptation of Lifelong Learning because we should not waste our time working on two different policies for one thing.*[8]

---

[2] Former Executive Director, NGO Education Partnership of Cambodia (NEP), Phnom Penh.
[3] Former Executive Director, NGO Education Partnership of Cambodia (NEP), Phnom Penh.
[4] See details: http://www.dvv-international.la/detail/news/the-first-step-towards-a-lifelong-learning-policy-in-cambodia/?tx_news_pi1%5Bcontroller%5D=News&tx_news_pi1%5Baction%5D=detail&cHash=53ec614f4df60bb47ac82ae3d32ab1e3
[5] Former Executive Director, NGO Education Partnership of Cambodia (NEP), Phnom Penh.
[6] Chief of Education, United Nations Educational, Scientific and Cultural Organization (UNESCO), Phnom Penh.
[7] Former Executive Director, NGO Education Partnership of Cambodia (NEP), Phnom Penh.
[8] Director of Department of Non-Formal Education, Ministry of Education Youth and Sports (MoEYS), Phnom Penh.

**Financing the Educational Sector in Cambodia**

According to *The Strategy for Educational Reform (2018–2023)*, the current focus of MoEYS is on academic management, financial management and human resource management. Each of these factors are essential for improving the quality of education in Cambodia and achieving Goal 2 of the Cambodia's customable development goals by 2030 (Hang, 2018). MoEYS's Education Strategic Plan has a clear goal of supporting the immediate and future economic growth and competitiveness of the nation in order to realise its ambitions. This depends on people having the right knowledge and relevant skills that reflect Cambodia's cultural and ethical heritage. In 2006, approximately US $946 million was spent driving educational development in Cambodia. Of this, 80.8% was provided by the government, with development partners providing 18.1% and loans making up 1.1%. According to the mid-term *Education Strategic Plan 2014–2018*, MoEYS invested US $764 million in 2016. In addition to this, development partners, including bilateral and multilateral agencies, allocated US $135.8 million to contribute to the implementation of the *Education Strategic Plan 2014–2018*. MoEYS has committed to gradually increasing the annual budget for education to US $1,033 million in 2019, US $1,368 million in 2023, US $1,804 million in 2028, and US $1,984 million in 2030. Such investment may help the Royal Government of Cambodia to reach its ambition of transitioning from a lower-middle income country to an upper-middle income country by 2030 and a developed country by 2050 (MoEYS, 2014). Development partners allocated 10.3% of the total official development assistance (ODA) in 2008. This rose to a peak of 14.1% in 2016 but dropped to 11.0% in 2017 and was only 7.4% in 2018. In order to replace these funds, educational loans increased from US $9.10 million in 2014 to US $24 million in 2018.

The largest proportion of MoEYS' annual budget is allocated for school-based management to ensure Cambodians achieve nine years of basic education (76.1% of the total annual budget in 2016). This further breaks down into spending on primary school (48.3%), lower secondary school (18.7%) and pre-school (9.1%). The Ministry allocated upper secondary (9.3%) and higher education (9.2%) similar proportions. However, only 2.9% (US $22.16 million) of the total annual budget in 2016 was allocated for non-formal education. A lecturer at the Faculty of Education observed that while the Non-Formal Education Department of MoEYS has made a strong effort to ensure that all children, youth, adults, poor people and those with disabilities realise their rights to a basic education and Lifelong Learning, only a limited number of rural and poor Cambodians have access to skills that can successfully support them to seek decent jobs. Some of the reasons for this are dependence on development partners and the limited budget from the government.[9] The Director of the Department of Non-Formal Education at MoEYS has appealed for more attention to be paid to non-formal education through budget allocations from the government and development partners because non-formal education is a very important contribution to achieving the SDG goals on education.

Lifelong Learning has been included in the SDGs to be achieved between 2015 and 2030. One of the Cambodia's 17 goals is SDG 4: "*Ensure inclusive and equitable quality education and promote lifelong learning opportunities for all*." Since Lifelong Learning is a global commitment, Cambodia through MoEYS will integrate it into the existing mechanism. A policy on Lifelong Learning is now in draft and waiting for endorsement from the Council of Ministers. Thirteen or 14 relevant ministries have been included to work on this new initiative. We also aim to work closely with NGOs and development partners who are enriched with both financial and human resources. For example, lessons learned and best practices of NGOs are useful to promote Lifelong Learning in Cambodia. However, this policy will not succeed unless all the relevant stakeholders work together. Lifelong Learning is a cross-cutting issue.[10] Lifelong Learning is one of the 12 prioritised programmes proposed in the *Education Strategic Plan 2014–2018*. The 10$^{th}$ prioritised programme was formulated as follows:

---

[9] Lecturer, Faculty of Education, Royal University of Phnom Penh, Phnom Penh.
[10] Director General of Policy and Planning Department, Ministry of Education Youth and Sports (MoEYS), Phnom Penh.

> *Literacy and Lifelong Learning program – equivalency programs and clearly defined mechanisms for literacy and Lifelong Learning to enable the country's human capital to continuously adapt to and benefit from emerging opportunities in the social, cultural and economic environment*. (MoEYS, 2014, pp. 15)

**Making the National Policy on Lifelong Learning a Reality**

During the fieldwork, people stated that they believed that their learning period ended after getting jobs; however, they did say they would consider going back to school if their knowledge and skills were not able to satisfy or achieve their employment goals as planned. Today, many people understand the importance of professional development throughout their life, especially when they have faced struggles and challenges in doing their job. The main goal of Lifelong Learning is to encourage people to consider learning as a non-stop activity so they keep updating their skills and knowledge to meet social, economic and technical changes. Lifelong Learning provides many individual benefits because skill advancement is highly correlated with knowledge and skills. For example, moving from one type of job to another requires learning new skills and improving knowledge to improve competency. Many countries work to improve economic growth, and governments work to guide learning for all of the people in the country. Lifelong Learning helps economic growth and helps people to become global citizens.[11]

A draft of the National Policy on Lifelong Learning was completed and has been submitted for endorsement at the Council of Ministers. In late 2018 or 2019, actions will be made in regard to Lifelong Learning in order to transform it into reality. Between 2000 and 2015, Cambodia adopted and localised the millennium development goals (MDGs). One of the nine goals, Goal 2, was accomplished in 2015 when the country achieved universal primary education. Post-MDG, Cambodia has continued to commit to achieving the 17 SDGs. Goal 4 requires the world to commit to ensuring inclusive and equitable quality education and promoting Lifelong Learning opportunities for all between 2015 and 2030. To achieve this, Cambodia has now developed a National Policy on Lifelong Learning. However, serious questions must be asked as to whether Cambodia is solving real problems or simply following buzzwords introduced by the United Nations. Moving from MDG to SDG with its own existing education system will be very difficult in the Cambodian context due to the limited government budget for education generally and in particular for the adaptation of Lifelong Learning. Various activities are required to promote Lifelong Learning, but quality and equity are key. Although Lifelong Learning is a new concept to Cambodia, the existing education strategic plan (ESP) already includes many key components of Lifelong Learning concepts. Lifelong Learning has two points: being flexible and learning for decent jobs.[12]

When people have the low capacity to pay for their individual education (a cost of approximately US $231 per person per year on average in Cambodia), support from government agencies and development partners is vital for bringing people back to school for professional development. In 2016, MoEYS invested US $764 million on education; of this, 94.6% of its national budget was allocated for formal education and only 2.9% was for non-formal education. There was no budget line clearly revealing from which section the Lifelong Learning programme budget would be allocated. If it is from the category of non-formal education, which appears most likely, then Lifelong Learning seemed to be only a buzzword that Cambodia has adopted in order to be aligned with international commitments. Therefore, to achieve Lifelong Learning, an increased budget from ODA and loans is essential. On average, ODA for the educational sector (2008 and 2018) and educational loans (2014–2018) were US $135.8 and US $14.3 respectively. They were mainly derived from bilateral agencies (i.e. United States Agency for International Development (USAID), Australian Agency for International Development (AusAID), Japan International Cooperation Agency (JICA) and Korea International Cooperation Agency (KOICA)), multi-lateral agencies (i.e., United Nations Educational, Scientific and Cultural Organization (UNESCO), United Nations Children's Fund is a United Nations Agency (UNICEF), and United

[11]Chief of Education, United Nations Educational, Scientific and Cultural Organization (UNESCO), Phnom Penh.
[12] Director General of Policy and Planning Department, Ministry of Education Youth and Sports (MoEYS), Phnom Penh.

Nations Development Programme (UNDP)) and international organisations (i.e., World Bank and Asian Development Bank (ADB). The international community should consider increasing the education budget for the non-formal and information educational sectors to ensure the Lifelong Learning programme is successful.

Bilateral, multilateral and international organisations have funded MoEYS activities and local NGOs are working in communities to support the educational sector; however, they have mainly funded activities implemented in Cambodia that contribute to international commitments, for example MDGs and SDGs. In this regard, the Lifelong Learning programme would benefit if and when the government of Cambodia allocates an extra budget for activities beyond those available within non-formal education. The available budget is already small and cannot support various activities such as classes for improving literacy and professional development and vocational training. The availability of a national budget for the Lifelong Learning Programme will not only sustain the long-term operation of the programme but also help to reduce international dependency. In 2015, Cambodia was re-classified as a lower-middle-income economy by the World Bank Group; its gross net income (GNI) per capita was then US $1,070. If the country meets its ambitious goal of transitioning from a lower-middle income country to an upper-middle income country by 2030 and a developed country by 2050, international aid will be automatically reduced and replaced with the national budget. Ensuring the improved knowledge and relevant skills for economic growth and the competitiveness of the nation that reflect Cambodia's cultural and ethical heritage will only happen if there is more investment via the national budget for improving formal, non-formal and informal education.

**Suggestions for Planning and Policy Implication**

***Develop a legal framework based on the National Policy on Lifelong Learning.*** After receiving endorsement from the Council of Ministers, MoEYS should establish a unit or a national task force in charge of Lifelong Learning. This unit or task force should work on a legal framework such as a strategic development plan and action plans to be aligned with the National Strategic Development Plan (NSDP), ESP and SDG indicators.

***Improve educational infrastructure and facilities for transferring knowledge and skills across the country.*** Improving the function and the operation of community-based learning centres can help to improve the transfer of non-formal and informal education. If possible, technologies and IT facilities should be fully equipped in order to allow people to upgrade their skills and knowledge.

***Increase access to informal education through social media.*** Many Cambodian people now have access to social media and networks, for example Facebook, Integrate, Telegram, WhatsApp and YouTube. These platforms play a very important role in sharing knowledge and improving skills and competence.

***Establish a coordination mechanism and monitoring and evaluation (M&E) system***. In order to track progress, an M&E system should be established that works in close coordination with MoEYS. The existing EMIS system is the best option as all of the indicators related to Lifelong Learning can be included in the system in order to track progress for reporting and evaluation. In addition to this, EMIS not only helps to reduce the cost of M&E implementation but also aligns with the existing ESP and NSDP.

**References**

CDC (2018) *Development Cooperation and Partnership Report*. Phnom Penh: Council for the Development of Cambodia.

Hang, C.R. (2018) Strategy for educational reform (2018-2023) Phnom Penh: Ministry of Education Youth and Sport.

MoEYS (2014) *Education Strategic Plan 2014-2018*. Phnom Penh: Ministry of Education Youth and Sport.

MoEYS (2016) *Education Strategic Plan 2014-2018*. Phnom Penh: Ministry of Education Youth and Sport.

ឯកសារសិក្សាគោលនយោបាយសង្ខេប
ការចេញផ្សាយលេខ០២ ឆ្នាំ២០១៨

ឯកសារបោះពុម្ពផ្សាយរបស់
ក្រុមប្រឹក្សាស្រាវជ្រាវអប់រំ

ការបោះផ្សាយនេះឧបត្ថម្ភដោយគម្រោងហិរញ្ញវត្ថុធនាគារអភិវឌ្ឍន៍អាស៊ី 2427 CAM (COL)

# ការរៀបចំផែនការ ការផ្តល់ហិរញ្ញប្បទាន និងការអនុវត្តកម្មវិធីការសិក្សាពេញមួយជីវិត

## គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពពាក់ព័ន្ធនឹងការអប់រំប្រកបដោយគុណភាពនៅកម្ពុជា

សុខ សូត្រ[1], ពៅ វណ្ណា[2] និងសុក សេរី[3]

[1]មហាវិទ្យាល័យអប់រំ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ [2]អង្គការ DVV International និង[3]ការិយាល័យស្រាវជ្រាវ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

ទំនាក់ទំនងអ្នកនិពន្ធ I សុក សេរី ការិយាល័យស្រាវជ្រាវ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ I អ៊ីម៉ែល៖ sok.serey@rupp.edu.kh

## ខ្លឹមសារសំខាន់ៗ


- ការសិក្សាពេញមួយជីវិត បានក្លាយជាទស្សនៈថ្មីមួយ និងជាមាគ៌ាអប់រំសម្រាប់ប្រទេសកម្ពុជាដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) របស់ខ្លួននៅត្រឹមឆ្នាំ ២០៣០។ ការសិក្សាពេញមួយជីវិត រួមបញ្ចូលនូវការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការផងដែរ ទោះបីជាមនុស្សមួយចំនួនមានការយល់ច្រលំថាវាគ្រាន់តែជាផ្នែកមួយនៃការអប់រំក្រៅប្រព័ន្ធតែប៉ុណ្ណោះក៏ដោយ។
- នៅឆ្នាំ ២០១៦ ក្រសួងអប់រំ យុវជន និងកីឡា បានប្រើប្រាស់ទឹកប្រាក់ចំនួន ១៧៤ លានដុល្លារអាមេរិក៖ ថវិកាប្រចាំឆ្នាំសរុបចំនួន ៧៦.១% ដើម្បីសម្រេចបាននូវការអប់រំកម្រិតមូលដ្ឋានរយៈពេល ៩ ឆ្នាំ (សាលាបឋមសិក្សា ៤៨.៣% សាលាមធ្យមសិក្សាបឋមភូមិ ១៨.៧% និងមត្តេយ្យសិក្សា ៩.១%)។ សាលាមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា បានទទួលថវិកាក្នុងចំនួនប្រហាក់ប្រហែលគ្នា ដែលកម្រិតនីមួយៗទទួលបាន ៩.២%។ ទោះបីជាការអប់រំក្រៅប្រព័ន្ធនាពេលបច្ចុប្បន្ននេះ ត្រូវបានគេជឿជាក់ថានឹងចូលរួមចំណែកក្នុងការផ្តល់នូវសកម្មភាពជាច្រើន ដើម្បីគាំទ្រដល់ការអប់រំពេញមួយជីវិតក៏ពិតមែន ក៏ប៉ុន្តែមានថវិកាប្រចាំឆ្នាំសរុបចំនួនត្រឹមតែ ២.៩% (ឬ ២២.១៦ លានដុល្លារអាមេរិក) ប៉ុណ្ណោះ ដែលត្រូវបានបែងចែកទៅដល់ផ្នែកនេះនៅក្នុងឆ្នាំ ២០១៦។
- ស្ថាប័នទ្វេភាគី ស្ថាប័នពហុភាគី និងអង្គការអន្តរជាតិនានា បានផ្តល់មូលនិធិដល់សកម្មភាពរបស់ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការក្រៅរដ្ឋាភិបាលមួយចំនួននៅក្នុងស្រុក ដើម្បីគាំទ្រដល់វិស័យអប់រំពាក់ព័ន្ធនឹងគោលដៅ MDGs និងគោលដៅ SDGs។ កម្មវិធីសិក្សាពេញមួយជីវិត អាចនឹងប្រព្រឹត្តទៅបានល្អ ប្រសិនបើរដ្ឋាភិបាលកម្ពុជាបែងចែងថវិកាបន្ថែមសម្រាប់សកម្មភាពទាំងនេះ លើសពីចំនួនដែលមាននាពេលបច្ចុប្បន្ននេះសម្រាប់វិស័យអប់រំក្រៅប្រព័ន្ធ។


## ការសិក្សាពេញមួយជីវិតនៅក្នុងប្រព័ន្ធអប់រំកម្ពុជា

គោលគំនិតនៃការសិក្សាពេញមួយជីវិតនេះ នៅតែជាទស្សនៈថ្មីនៅឡើយសម្រាប់ភ្នាក់ងាររដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានានៅក្នុងប្រទេសកម្ពុជា។ ហេតុដូច្នេះ មានសកម្មភាពតិចតួចតែប៉ុណ្ណោះ ដែលត្រូវបានអនុវត្តដើម្បីរួមចំណែកទៅក្នុងទស្សនៈនេះ។ ការសិក្សាពេញមួយជីវិត បានក្លាយជាគោលដៅជាមូលដ្ឋានគ្រឹះមួយនៃគោលនយោបាយអប់រំ

នៅក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ដោយគ្រប់គ្នាយល់ស្របថា ជាមធ្យោបាយមួយដើម្បីសម្រេចបាននូវការអភិវឌ្ឍសង្គម សេដ្ឋកិច្ច និងជាវិធីសាស្ត្រសម្រាប់លើកកម្ពស់សង្គមដោយឈរលើចំណេះដឹងជាមូលដ្ឋាន។ ការកើនឡើងនូវសារៈសំខាន់នៃការសិក្សាពេញមួយជីវិត ទាំងក្នុងគោលនយោបាយជាតិនិងអន្តរជាតិ នាំឱ្យមានតម្រូវការចាំបាច់ក្នុងការត្រួតពិនិត្យតាមដានយ៉ាងហ្មត់ចត់ និងល្អិតល្អន់បំផុតចំពោះអ្វីដែលអាចនឹងកើតមានឡើងពីកម្មវិធីនេះ។ ដើម្បីចាប់ផ្តើមប្រើប្រាស់ទស្សនៈនេះ យើងត្រូវតែយល់ដឹងអំពីការទទួលខុសត្រូវក្នុងការគ្រប់គ្រង ការផ្តល់ឱ្យ និងការគាំទ្រការសិក្សាពេញមួយជីវិត តាមរយៈឱកាសនៅក្នុងការបង្កើតការវិភាគ និងការអនុវត្តផ្ទាល់ខ្លួននៅក្នុងមជ្ឈដ្ឋានសេដ្ឋកិច្ច សង្គម បច្ចេកវិទ្យា និងគោលនយោបាយដែលមានការប្រែប្រួលឥតឈប់ឈរ[1] ។ អតីតប្រធានប្រតិបត្តិអង្គការក្រៅរដ្ឋាភិបាលមួយដែលមានឈ្មោះថា អង្គការភាពជាដៃគូអប់រំកម្ពុជា (NEP) គឺជាបុគ្គលលេចធ្លោមួយរូប និងមានបទពិសោធន៍ច្រើនក្នុងការងារសង្គមស៊ីវិលពាក់ព័ន្ធនឹងវិស័យអប់រំ ហើយបានផ្តល់នូវទិដ្ឋភាពទូទៅខ្លីៗខ្លះអំពីថា តើទស្សនៈនៃការសិក្សាពេញមួយជីវិតនេះត្រូវបានបញ្ចូលទៅក្នុងប្រទេសកម្ពុជាយ៉ាងដូចម្តេច។

> *នៅអឺរ៉ុប ការសិក្សាពេញមួយជីវិតនេះ ត្រូវបានដាក់ឱ្យអនុវត្តជាយូរណាស់មកហើយនៅតាមបណ្តាប្រទេសមួយចំនួនដូចជាប្រទេសអាល្លឺម៉ង់ជាដើម។ ប្រជាជននៅទីនោះសិក្សារៀនសូត្រនៅតាមផ្ទះ ទីសាធារណៈ និងនៅការិយាល័យ។ ពួកគេចូលចិត្តការអាន។ ការសិក្សាពេញមួយជីវិត គឺជាទស្សនៈថ្មីមួយនៅក្នុងប្រទេសកម្ពុជា ហើយត្រូវបានគេស្គាល់ជាលើកដំបូងនៅពេលដាក់ឱ្យអនុវត្តគោលដៅ SDGs។ មុនឆ្នាំ២០១៥ ការសិក្សាពេញមួយជីវិត មិនត្រូវបានយកមកពិភាក្សា ឬជជែកវែកញែកឡើងនៅក្នុងប្រទេសកម្ពុជា ហើយការអប់រំក្រៅប្រព័ន្ធមានការពេញនិយមជាខ្លាំង។ មកដល់ឆ្នាំ ២០១៥ នៅទីក្រុងអ៊ីនឆន ប្រទេសកូរ៉េខាងត្បូង គេបានចាប់ផ្តើមជជែកពិភាក្សាអំពីការសិក្សាពេញមួយជីវិត។ ពីមុនមកដល់ពេលនេះ មានអង្គការក្រៅរដ្ឋាភិបាលតិចតួចប៉ុណ្ណោះដែលកំពុងធ្វើការងារពាក់ព័ន្ធនឹងការសិក្សាពេញមួយជីវិត ដូចជាអង្គការ DVV ជាដើម*[2]។

នៅឆ្នាំ២០១០ មន្ត្រីរាជការមកពីក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបញ្ជូនទៅចូលរួមក្នុងការបណ្តុះបណ្តាលនៅប្រទេសអាល្លឺម៉ង់ ប្រទេសបែលហ្ស៊ិក និងប្រទេសហូឡង់។ បន្ទាប់ពីការបណ្តុះបណ្តាល ប្រតិភូកម្ពុជាបានជម្រាបជូនដំណឹងដល់ក្រសួងអប់រំ យុវជន និងកីឡា អំពីការសិក្សាពេញមួយជីវិតនេះ ប៉ុន្តែគ្មានចំណាត់ការណាមួយត្រូវបានធ្វើឡើងនៅពេលនោះទេ។ នៅខែតុលា ឆ្នាំ២០១៧ ប្រតិភូមកពីក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានបញ្ជូនទៅម្តងទៀតដើម្បីទទួលការបណ្តុះបណ្តាលស្តីពីការសិក្សាពេញមួយជីវិតនៅប្រទេសវៀតណាម។ នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១៧ ក្រសួងអប់រំ យុវជន និងកីឡាបានរៀបចំសិក្ខាសាលាជាលើកដំបូង ដោយមានការគាំទ្រពីអង្គការ UNESCO និងអង្គការ DVV។ ពួកគាត់ ជាអ្នកត្រួសត្រាយផ្លូវក្នុងការផ្តួចផ្តើមគំនិតអភិវឌ្ឍគោលនយោបាយស្តីពីការសិក្សាពេញមួយជីវិតនៅក្នុងប្រទេសកម្ពុជា។ បច្ចុប្បន្ននេះ គោលនយោបាយស្តីពីការសិក្សាពេញមួយជីវិត ត្រូវបានធ្វើសេចក្តីព្រាង

[1] សាកលវិទ្យាធិការរងទទួលបន្ទុកផ្នែកស្រាវជ្រាវនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

[2] អតីតប្រធានប្រតិបត្តិអង្គការក្រៅរដ្ឋាភិបាលមួយដែលមានឈ្មោះថា អង្គការភាពជាដៃគូកម្ពុជា (NEP) ទីក្រុងភ្នំពេញ។

និងវង់ថាំការអនុម័តសម្រេចដោយទីស្តីការគណៈរដ្ឋមន្ត្រី[3]។ កិច្ចប្រជុំជាន់ខ្ពស់រួមមួយ[4] ត្រូវបានស្នើឡើងដោយរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ឯកឧត្តមបណ្ឌិត ហង់ ជួនណារ៉ុន នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅសណ្ឋាគារសូហ្វីតែល រាជធានីភ្នំពេញ ដែលនេះគឺជាជំហានដំបូងឆ្ពោះទៅរកការបង្កើតគោលនយោបាយសិក្សាពេញមួយជីវិតនៅក្នុងប្រទេសកម្ពុជា។ កិច្ចប្រជុំអញ្ជើញចូលរួមដោយអ្នកតំណាងមកពីបណ្តាក្រសួងនានា ស្ថាប័នអង្គការ UNESCO សម្រាប់ការសិក្សាពេញមួយជីវិត បណ្តាញក្រសួងអប់រំនៃប្រទេសជាសមាជិកអាស៊ាន (SEAMEO CELLL) និងអង្គការអន្តរជាតិ DVV ដើម្បីស្វែងរកការយល់ដឹងរួមគ្នាទៅលើការសិក្សាពេញមួយជីវិត និងខ្លឹមសាររបស់វាជាអន្តរជាតិ និងនៅក្នុងបរិបទកម្ពុជា ដើម្បីត្រៀមរៀបចំសម្រាប់ការបកប្រែពន្យល់ទៅក្នុងក្របខណ្ឌច្បាប់ថ្នាក់ជាតិ។ ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា បានមានប្រសាសន៍បន្ថែមទៀតថា៖

> *គោលនយោបាយនេះ បានបង្កើតឡើងដោយមានការខិតខំប្រឹងប្រែង និងការគាំទ្រយ៉ាងពេញទំហឹងពីអង្គការ UNESCO បណ្តាញ SEAMEO CELLL អង្គការ DVV និងបណ្តាអង្គការជាតិ និងអន្តរជាតិផ្សេងទៀត ដែលអនុវត្តការងារដើម្បីគាំទ្រដល់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា។ មានបញ្ហាមួយចំនួនដែលអាចរាំងស្ទះដល់ការអនុវត្តការសិក្សាពេញមួយជីវិតនេះ បញ្ហាទាំងនោះរួមមានកម្មវិធីសិក្សា ផែនការយុទ្ធសាស្ត្រ និងយន្តការត្រួតពិនិត្យនិងវាយតម្លៃ ដើម្បីត្រួតពិនិត្យផែនការយុទ្ធសាស្ត្រនេះ[5]។*

បើតាមប្រធានផ្នែកអប់រំរបស់អង្គការ UNESCO ប្រចាំនៅទីក្រុងភ្នំពេញ បានលើកឡើងថា "ការសិក្សាពេញមួយជីវិត គឺជាតម្រូវការរបស់ប្រទេសកម្ពុជា។ ទស្សនៈនេះ ត្រូវបានដាក់ឱ្យអនុវត្តតាំងពីឆ្នាំ១៩៧២ ប៉ុន្តែវានៅតែថ្មីស្រឡាងសម្រាប់ប្រទេសកម្ពុជានេះ។ ក្នុងនាមជាអ្នកកាន់សាសនាហិណ្ឌូម្នាក់ ... យើងចាំបាច់ត្រូវសិក្សាគម្ពីរសាសនាហិណ្ឌូចាប់ពីពេលកើតដល់ស្លាប់។ ការសិក្សាអាចកើតមានគ្រប់ពេលវេលាទាំងអស់"[6]។ ប្រព័ន្ធអប់រំកម្ពុជា រួមមានការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ។ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ ត្រូវបានយកមកពិចារណាកាលពីកន្លងមកដែរ ក្រៅពីការអប់រំក្នុងប្រព័ន្ធ។ អតីតប្រធានប្រតិបត្តិអង្គការក្រៅរដ្ឋាភិបាលមួយឈ្មោះ អង្គការភាពជាដៃគូអប់រំកម្ពុជា (NEP) បានបង្ហាញថា ការសិក្សាពេញមួយជីវិត គឺមានលក្ខណៈទូលំទូលាយជាងការអប់រំក្រៅប្រព័ន្ធ។ ការសិក្សាពេញមួយជីវិត រួមមានការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ។ គ្រឹះស្ថាននានា អាចជួយលើកកម្ពស់ការទទួលបានបំណិន និងចំណេះដឹងអំពីបណ្តាសហគមន៍នៅតាមមូលដ្ឋាន។ ការសិក្សាពេញមួយជីវិត អាចអនុវត្តបានល្អ នៅពេលដែលគ្រឹះស្ថាននានាបំពាក់សម្ភារៈបរិក្ខារបានល្អ។ សហគមន៍

---

[3] អតីតប្រធានប្រតិបត្តិអង្គការក្រៅរដ្ឋាភិបាលមួយដែលមានឈ្មោះថា អង្គការភាពជាដៃគូកម្ពុជា (NEP) ទីក្រុងភ្នំពេញ។

[4] សូមអានសេចក្តីលម្អិត៖ http://www.dvv-international.la/detail/news/the-first-step-towards-a-lifelong-learning-policy-in-cambodia/?tx_news_pi1%5Bcontroller%5D=News&tx_news_pi1%5Baction%5D=detail&cHash=53ec614f4df60bb47ac82ae3d32ab1e3

[5] អតីតប្រធានប្រតិបត្តិអង្គការក្រៅរដ្ឋាភិបាលដែលមានឈ្មោះថា អង្គការភាពជាដៃគូកម្ពុជា (NEP) ទីក្រុងភ្នំពេញ។

[6] ប្រធានផ្នែកអប់រំនៃអង្គការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ នៃអង្គការសហប្រជាជាតិ (UNESCO) រាជធានីភ្នំពេញ។

នីមួយៗ មានតម្រូវការ និងការចង់បានផ្សេងៗគ្នា ដូច្នេះមជ្ឈមណ្ឌលអាចបំពេញការងារនៅក្នុងការចុះវាយតម្លៃលើតម្រូវការផ្នែកជំនាញ ដើម្បីកំណត់ពីតម្រូវការនៅតាមមូលដ្ឋាន[7] ។ ទន្ទឹមគ្នានេះដែរ ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡាបានផ្ដល់មតិយោបល់ដូចខាងក្រោមថា៖

> *ការអប់រំក្រៅប្រព័ន្ធ គឺជាផ្នែកមួយនៃការសិក្សាពេញមួយជីវិត ប៉ុន្តែយើងនៅមានការយល់ច្រឡំគ្នា។ អ្នកដើរតួនាទីសំខាន់មួយចំនួនបានអះអាងថា ការអប់រំក្រៅប្រព័ន្ធ គឺជាគំរូចាស់មួយ ហើយការសិក្សាពេញមួយជីវិត គប្បីដាក់ឱ្យប្រើជំនួសវិញ។ ការអប់រំក្រៅប្រព័ន្ធ អាចនឹងលែងមានប្រសិទ្ធភាព បន្ទាប់ពីមានអនុវត្តការសិក្សាពេញមួយជីវិតនេះ ដោយសារតែយើងមិនគួរខ្វះខ្ជាយពេលវេលារបស់យើងធ្វើការងារទៅលើគោលនយោបាយពីរផ្សេងគ្នាសម្រាប់រឿងតែមួយនោះឡើយ*[8]។

## ការផ្ដល់ហិរញ្ញប្បទានដល់វិស័យអប់រំនៅក្នុងប្រទេសកម្ពុជា

បើតាមយុទ្ធសាស្ត្រកំណែទម្រង់ (២០១៨-២០២៣) ក្រសួងអប់រំ យុវជន និងកីឡា បានផ្ដោតការយកចិត្តទុកដាក់ទៅលើការគ្រប់គ្រងការអប់រំសិក្សាធិការ ការគ្រប់គ្រងហិរញ្ញវត្ថុ និងការគ្រប់គ្រងធនធានមនុស្ស ទាំងអស់នេះគឺមានសារៈសំខាន់សម្រាប់ការលើកកម្ពស់ការអប់រំប្រកបដោយគុណភាព ដើម្បីសម្រេចបាននូវគោលដៅទី ២ នៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅត្រឹមឆ្នាំ២០៣០ (ហង់ ជួនណារ៉ុន, ២០១៨)។ ផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា មានគោលដៅច្បាស់លាស់ ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ចនាពេលបច្ចុប្បន្ន និងពេលអនាគត និងលទ្ធភាពប្រកួតប្រជែងរបស់ជាតិ ដើម្បីសម្រេចបានមហិច្ឆតារបស់ខ្លួន ដែលនេះអាស្រ័យលើអ្នកដែលមានចំណេះដឹង និងមានជំនាញពាក់ព័ន្ធ ដែលបង្ហាញពីកេរ្តិ៍ដំណែលវប្បធម៌ និងក្រមសីលធម៌របស់ប្រទេសជាតិ។ នៅក្នុងឆ្នាំ ២០០៦ ទឹកប្រាក់ប្រហែល ៩៤៦ លានដុល្លារអាមេរិក ត្រូវបានចំណាយដើម្បីជំរុញការអភិវឌ្ឍការអប់រំ ដែលទទួលបានពីរដ្ឋាភិបាល (៨០.៨%) ដៃគូអភិវឌ្ឍនានា (១៨.១%) និងប្រាក់កម្ចី (១.១%)។ យោងតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ ២០១៤-២០១៨ ក្រសួងអប់រំ យុវជន និងកីឡា បានវិនិយោគទឹកប្រាក់ចំនួន ៧៦៤ លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៦។ បន្ថែមលើនេះ ដៃគូអភិវឌ្ឍនានា រួមមានទីភ្នាក់ងារទ្វេភាគី និងពហុភាគី បានផ្ដល់ប្រាក់ចំនួន ១៣៥.៨ លានដុល្លាអាមេរិកសម្រាប់ចូលរួមចំណែកដល់ការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០១៤-២០១៨)។ ក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការបង្កើនកញ្ចប់ថវិកាប្រចាំឆ្នាំជាបន្តបន្ទាប់រហូតដល់ទឹកប្រាក់ ១,០៣៣ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៩ ទឹកប្រាក់ ១,៣៦៨ លានដុល្លារអាមេរិកក្នុងឆ្នាំ២០២៣ ទឹកប្រាក់ ១,៨០៤ លានដុល្លារអាមេរិកក្នុងឆ្នាំ ២០២៨ និងទឹកប្រាក់ចំនួន ១,៩៨៤ លានដុល្លារអាមេរិកក្នុងឆ្នាំ២០៣០។ ការវិនិយោគនេះអាចនឹងជួយរួមចំណែកដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការសម្រេចបាននូវគោលបំណងផ្លាស់ប្តូរពីប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតទាប ទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅត្រឹមឆ្នាំ២០៣០ និងក្លាយជាប្រទេសអភិវឌ្ឍនៅត្រឹមឆ្នាំ២០៥០ (ក្រ.អយក, ២០១៤)។ ក្រៅពីជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ដៃគូអភិវឌ្ឍន៍បាន

---

[7] អតីតប្រធានប្រតិបត្តិអង្គការក្រៅរដ្ឋាភិបាលដែលមានឈ្មោះថា អង្គការភាពជាដៃគូកម្ពុជា (NEP) ទីក្រុងភ្នំពេញ។

[8] ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ ក្រសួងអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ

ផ្តល់ប្រាក់ចំនួន ១០.៣% នៅក្នុងឆ្នាំ២០០៨ និងកើនឡើងដល់ចំនួនខ្ពស់បំផុត ១៤.១% ក្នុងឆ្នាំ២០១៦។ ជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) ក្នុងវិស័យអប់រំបានធ្លាក់ចុះមក ១១.០% នៅក្នុងឆ្នាំ ២០១៧ និងមកត្រឹម ៧.៤% តែប៉ុណ្ណោះនៅក្នុងឆ្នាំ២០១៨។ ជំនួសមកវិញ នូវប្រាក់កម្ចីវិស័យអប់រំបានកើនឡើងពី ៩.១០ លានដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៤ ទៅ ២៤ លានដុល្លារអាមេរិកក្នុងឆ្នាំ២០១៨។

ក្រសួងអប់រំ យុវជន និងកីឡា បានផ្តល់ប្រាក់យ៉ាងច្រើនសម្រាប់ការគ្រប់គ្រងនៅតាមសាលារៀន ដើម្បីសម្រេចបាននូវការអប់រំកម្រិតមូលដ្ឋានរយៈពេល ៩ ឆ្នាំ (៧៦.១% នៃកញ្ចប់ថវិកាសរុបនៅក្នុងឆ្នាំ២០១៦)៖ សាលាបឋមសិក្សា (៤៨.៣%) សាលាមធ្យមសិក្សាបឋមភូមិ (១៨.៧%) និងមត្តេយ្យសិក្សា (៩.១%)។ នៅកម្រិតមធ្យមសិក្សាទុតិយភូមិ (៩.៣%) និងកម្រិតឧត្តមសិក្សា (៩.២%) ក្រសួងអប់រំ បានផ្តល់ប្រាក់ដែលមានចំនួនសមមាត្រប្រហាក់ប្រហែលគ្នា។ ក៏ប៉ុន្តែ មានចំនួនទឹកប្រាក់ត្រឹម ២.៩% (ឬ ២២.១៦ លានដុល្លារសហរដ្ឋអាមេរិក) នៃចំនួនកញ្ចប់ថវិកាសរុបប្រចាំឆ្នាំតែប៉ុណ្ណោះ ដែលត្រូវបានផ្តល់ឱ្យសម្រាប់ការអប់រំក្រៅប្រព័ន្ធក្នុងឆ្នាំ ២០១៦។ សាស្ត្រាចារ្យមួយរូបនៅមហាវិទ្យាល័យអប់រំ បានសង្កេតឃើញថា នាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៃក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការធានាថាកុមារ យុវជន មនុស្សពេញវ័យ ជនទីទ័លក្រីក្រ និងជនដែលមានពិការភាពទាំងអស់ យល់ដឹងអំពីសិទ្ធិរបស់ពួកគេក្នុងការទទួលបានការអប់រំកម្រិតមូលដ្ឋាន និងការរៀនសូត្រពេញមួយជិវិត។ ប៉ុន្តែក្នុងចំណោមអ្នកទាំងនោះ មានមនុស្សតិចតួចណាស់ដែលទទួលបានជំនាញដែលអាចគាំទ្រពួកគេឱ្យទទួលបានជោគជ័យនៅក្នុងការស្វែងរកការងារសមរម្យបាន។ ការពឹងផ្អែកទៅលើដៃគូអភិវឌ្ឍន៍ និងកញ្ចប់ថវិកាមានកំណត់ពីររដ្ឋាភិបាល គឺជាមូលហេតុមួយចំនួននៅក្នុងចំណោមមូលហេតុទាំងនេះ[9] ។ ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធនៅក្រសួងអប់រំ យុវជន និងកីឡា បានធ្វើការអំពាវនាវសុំឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតទៅលើការអប់រំក្រៅប្រព័ន្ធ តាមរយៈកញ្ចប់ថវិកាដែលផ្តល់ដោយរដ្ឋាភិបាលនិងដៃគូអភិវឌ្ឍន៍នានា ដោយសារផ្នែកនេះពិតជាមានសារៈសំខាន់ណាស់ក្នុងការរួមចំណែកដល់ការសម្រេចបាននូវគោលដៅអប់រំនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាព។

ការសិក្សាពេញមួយជីវិត ត្រូវបានដាក់បញ្ចូលទៅក្នុងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (SDGs) ដែលត្រូវសម្រេចឱ្យបាននូវចន្លោះឆ្នាំ២០១៥ ដល់ឆ្នាំ២០៣០ ហើយគោលដៅ SDG ទី ៤ គឺជាគោលដៅមួយក្នុងចំណោមគោលដៅទាំង ១៧ នេះ។ *ធានានូវការអប់រំដែលមានគុណភាពប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសនៃការសិក្សាពេញមួយជីវិតសម្រាប់មនុស្សទាំងអស់គ្នា។* ដោយសារការសិក្សាពេញមួយជីវិត គឺជាការប្តេជ្ញាចិត្តជាសាកល យើងនឹងដាក់បញ្ចូលវាទៅក្នុងយន្តការដែលមានស្រាប់។ គោលនយោបាយស្តីពីការសិក្សាពេញមួយជីវិត បច្ចុប្បន្ននេះត្រូវបានធ្វើសេចក្តីព្រាង និងរង់ចាំការអនុម័តសម្រេចដោយទីស្តីការគណៈរដ្ឋមន្ត្រី។ យើងបានរួមបញ្ចូលក្រសួងពាក់ព័ន្ធចំនួន ១៣ ឬ ១៤ ដើម្បីធ្វើការងារលើគំនិតផ្តួចផ្តើមនេះ។ យើងក៏ត្រូវធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការក្រៅរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា ដែលមានភាពសម្បូរបែបទាំងផ្នែកហិរញ្ញវត្ថុ និងធនធានមនុស្ស។

[9] សាស្ត្រាចារ្យ មហាវិទ្យាល័យអប់រំ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ឧទាហរណ៍ មេរៀនដែលបានសិក្សារៀនសូត្រ និងការអនុវត្តប្រសើរបំផុតរបស់អង្គការក្រៅរដ្ឋាភិបាល គឺពិតជាមានសារៈប្រយោជន៍ណាស់ដើម្បីលើកកម្ពស់ការសិក្សាពេញមួយជីវិតនៅកម្ពុជា។ គោលនយោបាយនេះ នឹងអាចដំណើរការទៅបានល្អ លុះត្រាតែភាគីពាក់ព័ន្ធទាំងអស់ធ្វើការងាររួមគ្នា។ ការសិក្សាពេញមួយជីវិត គឺជាបញ្ហាអន្តរវិស័យមួយ[10]។ កម្មវិធីមួយក្នុងចំណោមកម្មវិធីអាទិភាពទាំង ១២ ដែលបានស្នើឡើងដោយផែនការយុទ្ធសាស្ត្រវិស័យអប់រំ (២០១៤-២០១៨) បានរួមបញ្ចូលផងដែរនូវការសិក្សាពេញមួយជីវិតនេះ ហើយកម្មវិធីអាទិភាពទី ១០ ត្រូវបានបង្កើតឡើងដូចខាងក្រោម៖

> *កម្មវិធីអក្ខរកម្ម និងការសិក្សាពេញមួយជីវិត – កម្មវិធីសមមូលមួយចំនួន និងយន្តការដែលមានការកំណត់ច្បាស់លាស់សម្រាប់អក្ខរកម្ម និងការសិក្សាពេញមួយជីវិត ដើម្បីអនុញ្ញាតឱ្យធនធានមនុស្សរបស់ប្រទេសអាចសម្របខ្លួនជាបន្តបន្ទាប់ និងទទួលបានអត្ថប្រយោជន៍ពីឱកាសថ្មីៗនៅក្នុងមជ្ឈដ្ឋានសង្គម វប្បធម៌ និងសេដ្ឋកិច្ច* (ក្រ.អយក, ២០១៤, ទំ. ១៥)។

## ការធ្វើឱ្យផែនការជាតិស្តីពីការសិក្សាពេញមួយជីវិតក្លាយជាការពិត

